BMI0126

# សម្ភាសន៍ជាមួយឈ្មោះ មាស វឿន ភេទប្រុស អាយុ៦៧ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“អនុកងពលទី១”

## រស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០១:៥៧:០៩

## ៤០ទំព័រ

ប៊ុន ថនៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ អ៊ំ អ៊ំឈ្មោះអីដែរ?

មាស វឿនៈ ខ្ញុំឈ្មោះ មាស វឿន ។

ប៊ុន ថនៈ អ៊ំឥឡូវអាយុប៉ុន្មានហើយ?

មាស វឿនៈ ខ្ញុំកើតនៅឆ្នាំ១៩៤៤ ។

ប៊ុន ថនៈ ចឹង៦០ជាង?

មាស វឿនៈ ៦៧ ។

ប៊ុន ថនៈ អ៊ំមានស្រុកកំណើតនៅណាដែរ?

មាស វឿនៈ ខ្ញុំមានស្រុកកំណើតនៅកំពង់ស្ពឺ ភូមិស្រែខ្ទុង ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

ប៊ុន ថនៈ ចឹងកាលពីដើមអ៊ំរៀនសូត្រដល់ណាដែរ?

មាស វឿនៈ ខ្ញុំកាលពីដើមមិនសូវបានរៀនសូត្រដូចគេទេ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៨ពីដើម ជំនាន់រាស្ត្រនិយម ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយប្រទេសយើងមានសភាពការណ៍ប្រែប្រួលទៅ ខ្ញុំបួសនៅវត្តវិញ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយខ្ញុំបានរៀននៅពេលបួសខ្លះ ។

ប៊ុន ថនៈ ចឹងបួលបានប៉ុន្មានវស្សាដែរ?

មាស វឿនៈ ខ្ញុំបួសបាន៥វស្សា ។

ប៊ុន ថនៈ បួសនៅវត្តណា?

មាស វឿនៈ ខ្ញុំបួសនៅវត្តព្រៃរមាថ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នៅក្នុងឃុំអូរ ។

ប៊ុន ថន: ចឹងក្រោយពីបួសមកអ៊ំធ្វើអីទៀត?

មាស រឿន: ក្រោយពីបួសមកខ្ញុំបាន សឹកមកវិញបានបំរើម៉ែឪហើយបានធ្វើការងារនយោបាយតាំងពីឆ្នាំ១៩៦៨ ក្នុងនោះមានមន្ត្រីកុងសីខ្វះ ដូចជាហ៊ូ យន់ ហ៊ូ នឹម ខៀវ សំផន គាត់មានទំនាស់ជាមួយសម្តេចសីហនុ ។

ប៊ុន ថន: បាទ ។

មាស រឿន: ចឹងហើយប្រទេសយើងមានការប្រែប្រួលច្រើន ខ្ញុំកាលហ្នឹងបាននៅក្នុងក្រុមយុវជនភូមិធ្វើការងារសម្ងាត់និងតស៊ូនយោបាយជំនាន់នោះ ។

ប៊ុន ថន: ចឹងអ៊ំធ្វើនៅភូមិបានយូរទេ?

មាស រឿន: ធ្វើនៅក្នុងភូមិបានប្រហែលជាពីរឆ្នាំ ឆ្នាំ១៩៦៨ ។

ប៊ុន ថន: បាទ!ពីឆ្នាំ៦៨ដល់រដ្ឋប្រហា?

មាស រឿន: ឆ្នាំ៦៨ជាយុវជនភូមិហ្នឹងធ្វើការងារនយោបាយជាមួយឯកសារហ៊ូ យន់ ខៀវ សំផន ៦៨-៦៩ដល់ឆ្នាំ៧០ បានមានការរដ្ឋប្រហា ។

ប៊ុន ថន: បាទ ។

មាស រឿន: នៅឆ្នាំរដ្ឋប្រហាខ្ញុំដេកព្រៃរហូតឆ្នាំ៦៨-៦៩ដល់ឆ្នាំ៧០ បានខ្ញុំចូលភូមិវិញ ។

ប៊ុន ថន: ចឹងបងប្អូនអ៊ំនៅក្នុងភូមិ?

មាស រឿន: បងប្អូនខ្ញុំដល់ខ្ញុំចេញមកព្រៃមក គេថាខ្ញុំបំរើកិច្ចការងារខ្មែរក្រហមពេលនោះបងខ្ញុំឈ្មោះអ៊ុនហ្នឹងអាយុប្រហែលជា៣០ឆ្នាំ គេចាប់យកទៅសម្លាប់នៅឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺហ្នឹង ជំនាន់ លន់ នល់ ហើយក្រោយមកទៀតប្អូនស្លាប់ដោយសារគេចាប់ដែរ ហើយក្រោមមកទៀតឪពុកមាខ្ញុំត្រូវគេចាប់ដែរ ដោយសារតែខ្ញុំជាប់និន្នាការជាមួយខ្មែរក្រហម ។

ប៊ុន ថន: បាទ ។

មាស រឿន: កាលជំនាន់នោះ ។

ប៊ុន ថន: ចឹងកាលអ៊ំចូលជំបូង ចូលជាមួយពីណា?

មាស រឿន: កាលខ្ញុំចូលដំបូងមានកម្មាភិបាលគេសម្ងាត់នៅក្នុងភូមិម្នាក់ គេមកនិយាយប្រាប់ខ្ញុំថាប្រទេសយើងមិនមានឯករាជ្យទេ ដូចនេះសេដ្ឋកិច្ចនៅក្នុងកណ្តាប់ដៃមូលធន នាយទុន ។

ប៊ុន ថន: បាទ ។

មាស វឿនៈ មូលធន នាយទន់ហ្នឹងមានន័យថា របបអ្វីទាំងអស់នៅក្រោមអាណានិគមរបស់បារាំងទាំងអស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដូច្នេះបន្ទាប់មកបានមានខ្មែរ ចិនអាណានិគមទាំងអស់វាមានតែបារាំងគ្រប់គ្រងទាំងអស់ ដូចជារោងចក្រទឹកក្រូច ចំការកៅស៊ូរោងចក្រធំៗនៅលើបារាំងទាំងអស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ខ្មែរយើងមិនមានសិទ្ធអំណាចអីទេ ។

ប៊ុន ថនៈ ចឹងគាត់នៅរស់ទេ អីដែលបានប្រាប់អីហ្នឹង?

មាស វឿនៈ គាត់ស្លាប់ហើយ អ្នកដឹកនាំខ្ញុំហ្នឹងគាត់ស្លាប់ហើយដោយសារគេចាប់គាត់ គេចាប់គាត់ក្នុងសម័យឆ្នាំ៧៥ ។

ប៊ុន ថនៈ បាទ!ចឹងការងារនៅព្រៃហ្នឹងកាន់ខាងឯកសារអីទេ?

មាស វឿនៈ ការងារខ្ញុំចេញមកព្រៃហើយដោយសារខ្ញុំខ្លាចភ្នាក់ងារខាងទាហានលន់ នល់ ចឹងមានគិញសម្ងាត់គេចេញស៊ើបការណ៍ចឹងហើយខ្ញុំចេញដេកព្រៃភ្នំ ខ្ញុំដេកព្រៃភ្នំខ្ញុំជានិរសាឬជាកងការពារអ្នកដឹកនាំកម្មាភិបាលសម្ងាត់ទាក់ទងគ្នារវាងកំពង់ស្ពឺមកខាងពោធិសាត់ បាត់ដំបងតាមតែគេចួបជុំគ្នាសម្ងាត់គេដើរតាមសម្ងាត់គេដើរតាមព្រៃ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងមានថ្នាក់ដឹកនាំគេចុះមកទេ?

មាស វឿនៈ ថ្នាក់ដឹកនាំគេចុះមកដែរ គេមកតាមក្រុងគេចុះមកតាមផ្លូវជាតិលេខ៤ យើងនៅព្រៃចាំទទួលគេ ខាងនិរសាក្រុងគេច្រើនប្រើបុណ្យសក្តិគេ ដូចជាអ្នកនាំសារពីភ្នំពេញមកដល់ជនបទហ្នឹង កាលហ្នឹងគេទិញសក្តិ៥ ប៉េអ៊ឹមពាក់ ដូចមកចឹងទៅគេសន្យាថាឲ្យមកជួបគេនៅកន្លែងនេះៗយើងមកជួបគេទៅ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយយើងនាំសារហ្នឹងមកប្រាប់អ្នកដឹកនាំនៅតាមជនបទហ្នឹងមក ។

ប៊ុន ថនៈ កាលហ្នឹងមានពីណាខ្លះ?

មាស វឿនៈ កាលហ្នឹងភ្នាក់ងារដែលគេនាំសារហ្នឹង គេនាំដំណឹងហ្នឹងមកគេអ្នកដឹកនាំនៅទីក្រុងភ្នំពេញយើងមិនបានដឹងច្បាស់ទេ ការពិតយើងគ្រាន់តែបានដឹងថា លោកខៀវ សំផន ហ៊ូ យន់គាត់ជាអ្នកមានមុខមាត់មុនគេបង្អស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ព្រោះកាលហ្នឹងសម្ដេចសីហនុគាត់កាត់ទោសខៀវ សំផន ហ៊ូ នឹម ហ៊ូ យន់ កាត់ទោស ។

ប៊ុន ថនៈ បាទ!ចឹងវ៉ន វ៉េតអីគាត់មានបានមកដល់ហ្នឹងទេ?

មាស វឿនៈ ក្នុងឆ្នាំ៦៨ ហ៊ូ យន់គាត់ចេញមកព្រៃហើយ ខៀវ សំផន ចេញមកព្រៃហើយ កាល ហ្នឹង វ៉ន វ៉េត គាត់ចេញមកព្រៃតែគាត់អាចចូលទៅក្នុងវិញបាន បើគាត់មានបញ្ហាអី គាត់ចេញមកព្រៃវិញ ចំណែកវ៉ន វ៉េត ។

ប៊ុន ថនៈ ចឹងគាត់ចេញចូលបាន?

មាស វឿនៈ បាទ!ចេញចូលបាន ព្រោះនិរសាយើងពាក់សក្ដិ៥ម៉េអ៊ឹមហើយ វាធំណាស់ ខាងវ៉ន វ៉េតកាលនោះ ។

ប៊ុន ថនៈ ចឹងដល់ពេលរដ្ឋប្រហារហើយបានពួចូលមក?

មាស វឿនៈ អាហ្នឹងដំណាក់កាលសម្ងាត់នៅឡើយ ដល់ឆ្នាំ១៩៧០ជាឆ្នាំរដ្ឋប្រហាររបស់សម្ដេចសីហនុ នៅឆ្នាំ១៩៧០កើតរដ្ឋប្រហាហ្នឹងយើងមិនទាន់មានមូលដ្ឋានត្រឹមត្រូវទេ ដូចនេះនៅក្នុង កំណាច់ដៃរបស់លន់ នល់ ដល់ពេលយើងមានកំលាំងខ្លះនៅឆ្នាំ១៩៧០ឬពាក់កណ្ដាល នៅឆ្នាំ១៩៧០យើងមានកងវរៈពីវវរៈសេនាតូច សម្រាប់ការពារពារអ្នកដឹកនាំកម្មាភិ បាលជំនាន់នោះ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ការពារសាស្ត្រចារប្អ្នកស្នេហាជាតិ យើងជាអ្នកការពារគេ ។

ប៊ុន ថនៈ ចឹងយើងបែកចែកជាពីវរៈ?

មាស វឿនៈ បាទ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងពីណាជាអ្នកគ្រប់គ្រង?

មាស វឿនៈ អ្នកការពារអ្នកដឹកនាំហ្នឹង មានឈ្មោះ សឿងគាត់ជាប្រធានខ្ញុំ គាត់ជាអ្នកគ្រប់គ្រងពីរវរៈ សេនាតូចហ្នឹង មិនជាច្រើនប៉ុន្មានទេវរៈសេនាតូចជំនាន់នោះមិនសូវមានកាំភ្លើងប៉ុន្មានទេ មានតិចតួចណាស់ មានប្រហែលជា១០ទៅ២០ដើមប៉ុណ្ណឹងឯង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ តែសព្វថ្ងៃគាត់ស្លាប់ហើយ ។

ប៊ុន ថនៈ ចឹងមួយវរៈទៀត?

មាស វឿនៈ គាត់គ្រប់គ្រងទាំងពីរវរៈហ្នឹងឯង តែមេក្រុមអីហ្នឹងភ្លេចគ្នាអស់ហើយ វាបែកគ្នាយូរពេក ទៅភ្លេចឈ្មោះគ្នាអស់ហើយ ។

ប៊ុន ថនៈ ចឹងទីតាំងក្នុងភូមិហ្នឹងមានអាហារលន់ នល់ចូលនៅបានទេ?

មាស វឿនៈ នៅក្នុងភូមិហ្នឹងពីដើមគេកេណ្ឌធ្វើជាភូមិយុទ្ធសាស្ត្រ ភូមិយុទ្ធសាស្ត្រហ្នឹងមិនឲ្យមាននរណាចូលបានទេ ដោយមានប៉ូលីសនិងអាហានការពារទាំងយប់ទាំងថ្ងៃ ហើយគ្រួសារយើងនៅក្នុងវង់ភូមិយុទ្ធសាស្ត្រ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ មានគេគ្រប់គ្រង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ចឹងគេមានដាក់របងជុំវិញ មិនអាចចូលបានទេយប់ ទាល់តែមានភ្នាក់ងារយើងមកខ្សិបខ្សៀវថាចូលកន្លែងនេះបាន បានយើងចូល យើងលួនចូលទៅលាក់ការណ៍ជួបគ្នាបានប្រហែលជា១០ទៅ២០នាទីយើងចេញមកវិញមក ។

ប៊ុន ថនៈ ចឹងក្រោយមានរដ្ឋប្រហារហើយ ការទាក់ទងគ្នាកាន់តែមានច្រើនទេ?

មាស វឿនៈ ក្រោយរដ្ឋប្រហារមានកសាងកំលាំងប្រដាប់អាវុធ បានតាមភូមិខ្លះបានតាមឃុំខ្លះ គេមានមូលដ្ឋានរំដោះខ្លះ អាហារលន់ នល់គេក៏មានអំណាចគ្រប់គ្រងតែបន្ទាយគេមួយទៅយើងអាចដើរបានខ្លះទៅដឹង ចឹងកន្លែងណាចន្លោះយើងដើរបាន ឬគេគ្រប់គ្រងទីប្រជុំជនអីយើងមិនអាចដើរបានទេ ។

ប៊ុន ថនៈ ចឹងមានកម្មាភិបាលមកពីភ្នំពេញក្រោយៗទៀតទេ?

មាស វឿនៈ អ្នកដែលមកពីភ្នំពេញចាប់ពីឆ្នាំរដ្ឋប្រហារហើយគឺដាច់ខ្សែមិនអាចទាក់ទងគ្នាបានទេ បានតែមុនឆ្នាំ៧០បន្តិច ឆ្នាំ៦៧-៦៨ ណាដែលគេបែកមុខចេញមកមិនបានទៅវិញទេ ដល់ឆ្នាំ៧០រដ្ឋប្រហារហើយ សភាពការណ៍ខាងលន់ នល់តឹងតែងណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គេហាមមិនឲ្យចេញចូល គេហាមមិនឲ្យទាក់ទង បិតផ្លូវសេដ្ឋកិច្ចតាមភូមិតាមស្រុកគេតឹងតែងទាំងអស់ ។

ប៊ុន ថនៈ ចឹងតា ចេង អនអីហ្នឹងយ៉ាងម៉េចដែរ?

មាស វឿនៈ តា ចេង អន គាត់ជាមួយខ្ញុំហ្នឹងឯង គាត់មកជាមួយខ្ញុំខាងពាណិជ្ជកម្មរបស់អង្គការគេ ។

ប៊ុន ថនៈ បាទ!កាលហ្នឹងពាណិជ្ជកម្មរដ្ឋ?

មាស វឿនៈ ហ្នឹងហើយពាណិជ្ជកម្មរដ្ឋ ចេង អនហ្នឹងដើរព្រៃជាមួយខ្ញុំហ្នឹងហើយ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ចេង អនហ្នឹងគាត់ជាអ្នកព្រៃជាមួយខ្ញុំរហូត ។

ប៊ុន ថនៈ ចឹងពូនៅកន្លែងហ្នឹងរហូតឬមួយផ្លាស់ទៅតំបន់ណាផ្សេងទៀត?

មាស វឿនៈ ក្នុងពេលរដ្ឋប្រហារហើយខ្ញុំចេញពីស្រុកខ្ញុំមកហើយ ខ្ញុំមកនៅកំពង់ឆ្នាំង ខ្ញុំនៅកំពង់ឆ្នាំង៤ ឆ្នាំ ហើយខ្ញុំមិនបានទៅស្រុកវិញទេ រហូតដល់ថ្ងៃនេះ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដោយសារខ្ញុំមិនបានទៅស្រុកដោយសារខ្ញុំបែកបងប្អូនតាំងពីឆ្នាំ១៩៦៨ ដល់ឆ្នាំ៧៥ក៏មិនបានទៅស្រុក ដល់ថ្ងៃនេះក៏ខ្ញុំមិនបានទៅស្រុក ខ្ញុំគ្មានសាហ៊ុយដើរផង ខ្ញុំគ្មានមធ្យោបាយ ។

ប៊ុន ថនៈ បាទ!ចឹងមានដែលបានដំណឹងបងប្អូននៅទីនោះទេ?

មាស វឿនៈ បងប្អូនខ្ញុំស្លាប់អស់ហើយ នៅសល់តែខ្ញុំម្នាក់ឯង ខ្ញុំមានតែប្អូនស្រីមួយទេ នៅរស់នៅម៉ាឡៃ តែប៉ុន្មានខែមុននេះស្លាប់ហើយ ។

ប៊ុន ថនៈ ចឹងមាននៅម៉ាឡៃដែរ?

មាស វឿនៈ បងប្អូនខ្ញុំនៅម៉ាឡៃ នៅប៉ៃលិន នៅសំឡូត បងប្អូនខ្ញុំនៅតាមម៉ាជួរនេះចាប់ពីម៉ាឡៃទៅដល់សំឡូត សព្វថ្ងៃខ្ញុំនៅតែម្នាក់ឯងទេ ។

ប៊ុន ថនៈ ចឹងកាលដែលអ៊ំនៅកំពង់ឆ្នាំងហ្នឹង កាលហ្នឹងគេរៀបជាសហករណ៍តំបន់អស់ហើយនៅ?

មាស វឿនៈ ខ្ញុំចេញពីស្រុកខ្ញុំមកនៅឆ្នាំ១៩៦៨ មកនៅកំពង់ឆ្នាំ៦៨-៦៩និង៧០ចាប់ផ្ដើមរដ្ឋប្រហារខ្ញុំធ្វើជាទាហានទាំងអស់ ខ្ញុំមិនបានប្រឡូកការងារក្នុងសហករណ៍ឬរបស់តំបន់ខ្ញុំមិនបានធ្វើទេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ខ្ញុំមិនបានដឹងកិច្ចការងារខាងតំបន់និងសហករណ៍ទេ ទាហានខ្ញុំដឹងទាំងអស់ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងគេមានបែងចែកជាកងវរៈកងពលអីទេ?

មាស វឿនៈ នៅឆ្នាំ៧០ហ្នឹងមានគេបែកចែកជាកងវរៈសេនាតូច មានកងពលអីខ្លះ តែមិនទាន់គ្រប់ជាអង្គភាពទេ តែមានជាកងទ័ពគេគ្រាន់ច្រើនដែលហើយមានបីកងវរៈសេនាតូច កាលហ្នឹងមានសៀងតែខ្ញុំមិនបានដឹងថាត្រកូលគាត់ឈ្មោះអីទេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ឈ្មោះ សៀនហ្នឹងគាត់នៅតាកែវ គាត់គ្រប់គ្រងកាន់កាប់បីវរៈសេនាតូចហ្នឹង នៅខេត្តកំពង់ឆ្នាំងតាំងពីឆ្នាំ១៩៧០រហូត ដល់ឆ្នាំ១៩៧៥គាត់ជាប្រធានវរៈសេនាតូចទាំងបីកងហ្នឹង គាត់បានទទួលដល់កងពលទី១កាលនៅជាកងទ័ពហ្នឹង ។

ប៊ុន ថនៈ ចឹងអ៊ំនៅជាមួយគាត់រហូត?

មាស វឿនៈ កាលហ្នឹងគាត់ជាប្រធាន ខ្ញុំជាអនុគាត់ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងអ៊ំឡើងទៅសមរភូមិណាខ្លះអ៊ំ?

មាស វឿនៈ នៅខេត្តកំពង់ឆ្នាំងហ្នឹង សមរភូមិដែលខ្ញុំធ្វើសកម្មភាពច្បាំងជាមួយទាហានលន់ នល់ហ្នឹងចាប់តាំងពីខេត្តកំពង់ឆ្នាំង រហូតដល់ខេត្តពោធិសាត់នៅម៉ុំគគរ ស្រុកគគរ ពន្លៃគគរ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ពន្លៃគគរ កំពង់ឆ្នាំងទល់គ្នាហ្នឹងខដុងកំពង់លួង លង្វែកទៅដល់ចឹងសំរោងបព្រែកព្នៅ ។

ប៊ុន ថនៈ ចឹងអ៊ំទទួលមុខសញ្ញាហ្នឹង?

មាស វឿនៈ ហ្នឹងហើយទទួលមុខសញ្ញាហ្នឹងរហូត ។

ប៊ុន ថនៈ ចឹងកាលហ្នឹងមានវៃខ្លាំងដែរ?

មាស វឿនៈ កាលហ្នឹងវៃខ្លាំងដែលហ្នឹង សម័យហ្នឹងបើសមរភូមិហ្នឹងពីរដូវប្រាំងដល់រដូវវស្សា ពីរដូវវស្សាដល់រដូវប្រាំង កាលហ្នឹងកំលាំងយើងក៏មានក្រាស់ក្រើលដែរ ហើយកំលាំងខាងលន់នល់ក៏គេមានក្រាស់ក្រើលដែលណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយក្នុងហ្នឹងកងពលរបស់លន់ នល់ មានលោកឧត្តមសេនីយអ៊ំ សាវុធមួយនិងកងទ្រង់ច័ន្ទរាំងស្វីគេប្រតិបត្តិការតាមផ្លូវហ្នឹងដែរ តែគេវៃខ្លាំងហើយយើងបើមិនបានទេ ដាច់តាំងពីខដុងមកទល់គ្នាហ្នឹងកំពង់ឆ្នាំង មកទល់គ្នាហ្នឹងពន្លៃបរិបូណ៌ ។

ប៊ុន ថនៈ ចឹងកងពលហ្នឹងបែងចែកដាច់ពីភូមិភាគ?

មាស វឿនៈ កងពលនេះនៅក្នុងភូមិភាគ ។

ប៊ុន ថនៈ នៅក្នុងភូមិភាគណា?

មាស វឿនៈ នៅក្នុងភូមិភាគបញ្ចឹម ។

ប៊ុន ថនៈ ចឹងកាលហ្នឹងកង ចាបគាត់ជាប្រធាន?

មាស វឿនៈ អត់មានកង ចាបនៅក្នុងហ្នឹងទេ កង ចាបនៅខាងតំបន់ភូមិភាគពាយ័ព្យទេ ។

ប៊ុន ថនៈ ពាយ័ព្យរស់ ញឹម?

មាស វឿនៈ មើល កាលហ្នឹងខ្ញុំមិនដឹងថា រស់ ញឹមប្តូកងចាបខ្ញុំមិនបានដឹងដែរ ។

ប៊ុន ថនៈ ចឹងកុយ ធួន?

មាស វឿនៈ ខ្ញុំមានឮឈ្មោះគាត់ តែខ្ញុំមិនច្បាស់ជាមួយគាត់ តែគាត់អាចទទួលមន្ទីរភូមិភាគសេនាធិការប្រហែលជាចឹងដឹង ។

ប៊ុន ថនៈ ក្រោយមកគាត់មកខាងពាណិជ្ជកម្ម ដឹបូងគាត់ជាគណៈភូមិភាគ ។

មាស វឿនៈ ខ្ញុំមិនបានច្បាស់ជាមួយគាត់ទេ ។

ប៊ុន ថនៈ កាលហ្នឹងកង ចាបពីដើមគាត់នៅខាងបញ្ចឹម ក្រោយមកគេដូរមកសៀបរាម ។

មាស វឿនៈ ខ្ញុំមិនបានដឹង តែតា ស៊ី ជួ ដេតភូមិភាគបញ្ចឹម បើកង ចាបនិងរស់ ញឹមប្រហែលជាគាត់នៅពាយ័ព្យប្តូសៀមរាបខ្ញុំមិនបានដឹង តែខាងបញ្ចឹមមានតែ តាស៊ីម្នាក់ទេនិងប្រធាន ខ្ញុំឈ្មោះសឿងនេះ ព្រោះកាលហ្នឹងមានកងពលមានគណៈភូមិភាគចឹងរដ្ឋអំណាចក្រោយ ហ្នឹងមានពីរ ។

ប៊ុន ថនៈ ចឹងអ្នកទទួលបន្ទុកមាននយោបាយមានកងទ័ព?

មាស វឿនៈ ហ្នឹងហើយ តែខាងនេះខ្ញុំមិនបានដឹងទេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ជំនាន់ហ្នឹងខ្ញុំមិនបានចេញចូលទេ ។

ប៊ុន ថនៈ ចឹងកាលវ៉ៃចូលទៅភ្នំពេញហ្នឹងមានខូចខាតកំលាំងអីច្រើនទេ?

មាស វឿនៈ ដល់សមរភូមិភ្នំពេញ គេហៅថាសមរភូមិ៩៩០ជាសមរភូមិវ៉ៃចូលទីក្រុងភ្នំពេញ គេហៅថាសមរភូមិ៩៩០ កាលហ្នឹងមានកងពលខាងឧត្តរ មានកងពលខាងបូព៌ា មានកងពលខាងនិរតី មានកងពលខាងបញ្ចឹម ដូច្នេះគេមានប្រកគេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដូច្នេះគេមានប៉ុន្មានកងពល ដែលគេហ៊ុមវ៉ៃចូលទីក្រុងភ្នំពេញហ្នឹងវាមានច្រើនកងពលប្រហែលជាមាន១២កងពល ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ក៏ប៉ុន្តែមុខសញ្ញាគេមួយៗ គេចែកមុខសញ្ញាតាមភូមិភាគគេ អគ្គមេបញ្ជាការគេចែកភូមិភាគគ្នា ដូចជាខាងនិរតីគេចូលពីខាងណា បញ្ចឹមចូលពីខាងណា បូព៌ាចូលពីខាងណា អាហ្នឹងគេមានមុខសញ្ញារបស់គេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយទៅចាប់ដៃគ្នានៅកន្លែងណា អាហ្នឹងគេមានមុខសញ្ញាគេ យើងទៅចាប់ដៃគ្នានៅកន្លែងអគ្គមេបញ្ជាការលន់ នល់ យើងចាប់ដៃគ្នានៅកន្លែងហ្នឹងឯង មុខសញ្ញាដែលគេវៃឈ្នះហើយ តែខាងបូព៌ាគេចូលតាមបូព៌ា ពាយ័ព្យគេចូលតាមពាយ័ព្យ ខាងឧត្តរចូលតាមឧត្តរ និរតីចូលខាងនិរតី តែគេទៅចាប់ដៃគ្នានៅកន្លែងអគ្គមេបញ្ជាការលន់ នល់ ។

ប៉ុន ថនៈ ចឹងមានដឹងថាខាងណាវៃចូលបានមុន?

មាស វឿនៈ កាលហ្នឹងខាងបូព៌ាវៃបានចូលមុន ក្រោយមកបានខាងនិរតីខាងបញ្ចឹម ខាងពាយ័ព្យចូលរួមចាប់ដៃគ្នា ។

ប៉ុន ថនៈ ចឹងក្រុមអ៊ំចូលតាមណា?

មាស វឿនៈ កាលហ្នឹងចូលតាមពោធិចិនតុង ចឹងប្រយ៉ាបទៅដល់ស្ទឹងមានជ័យទៅចាប់ដៃគ្នានៅកន្លែងហ្នឹងឯង ។

ប៉ុន ថនៈ ចឹងថ្ងៃណាអ៊ំវៃចូលដល់?

មាស វឿនៈ កាលហ្នឹងគេឲ្យឈ្នះថ្ងៃទី១៨ តែគេវៃឈ្នះទី១៧មេសា ។

ប៉ុន ថនៈ ចឹងយ៉ាងម៉េចគេចង់ដាក់១៨វិញ?

មាស វឿនៈ នៅក្នុងគំរោងការគេ អគ្គមេបញ្ជាការឲ្យវៃឈ្នះនៅថ្ងៃទី១៨ តែដល់យើងវៃទៅ ស្រាប់តែឈ្នះនៅថ្ងៃទី១៧វិញ ។

ប៉ុន ថនៈ ចឹងហើយមុនផែនការ?

មាស វឿនៈ ហ្នឹងហើយ ហើយមុនផែនការ ដូច្នេះសម្រេចមុនផែនការ ដូចនេះត្រូវឈ្នះថ្ងៃទី១៧មេសាវិញ ប្រហែលជាម៉ោង៩...ម៉ោង១១ថ្ងៃ ។

ប៉ុន ថនៈ ចឹងនៅពេលវៃដល់ហ្នឹងខាងកងទ័ពគេរៀបចំយ៉ាងម៉េចអ៊ំជាមួយរដ្ឋកាលចាស់អ៊ីចឹង?

មាស វឿនៈ នៅពេលវៃឈ្នះហើយទាហានខាងលន់ នល់ហ្នឹងគេនៅស្ងៀមទាំងអស់ គេចង"ទង់ស" តាមផ្ទះថ្មួ តែទាហានលន់ នល់ពាក់ឯកសណ្ឋានតែកាំភ្លើងគេមិនមានកាន់ទេ គេនៅធម្មតា គេមិនបានទៅណាមកណាទេ គេនៅចាំទទួលផែនការយ៉ាងម៉េចៗយើងមិនដឹងទេ យើងក៏មិន មានវៃទៀតទេ ។

ប៉ុន ថនៈ បាទ ។

មាស វឿនៈ ចឹងនៅចូលដល់ហើយយើងមិនមានផ្ទុះអាវុធអីទៀតទេ ។

ប៉ុន ថនៈ ចឹងមេៗទាហានខាងលន់ នល់ចឹងធ្វើម៉េចទៅ?

មាស វឿនៈ កាលហ្នឹងដូចជាលោកលន់ នល់ហ្នឹងគាត់ទៅអាមេរិចហើយ ។

ប៊ុន ថន៖ ចឹងនៅក្រោមគាត់ទៀតគេរៀបចំយ៉ាងម៉េចដែរ?

មាស វឿន៖ ក្រោមៗទៀតហ្នឹងខ្ញុំមិនបានដឹងដែរ ខ្ញុំមិនដឹងជាគេយកទៅខាងណា ខាងណីនៅពេលដែល យើងរំដោះភ្នំពេញហើយ ទាហានលន់ នល់គាត់ចុះចាញ់ហើយ គេប្រមូលអាវុធរក គ្រឿងគ្រាប់ផ្ទុះអីហ្នឹង កាលហ្នឹងក្នុងរយៈមួយអាទិត្យហ្នឹងគេឲ្យយើងចេញទៅ គេរៀបចំខាងក្រោយយ៉ាងម៉េចយើងមិនបានដឹងទេ។

ប៊ុន ថន៖ បាទ។

មាស វឿន៖ ហើយគេជម្លៀសយ៉ាងម៉េចៗយើងមិនបានដឹងទេ កាលហ្នឹងខ្ញុំចេញផុតហើយគេមិនឲ្យយើងទៅប្រឌូលប្រឌលជាមួយគេ ព្រោះយើងជាទាហានមិនឲ្យមានប្រឌូលប្រឌល់ទេ។

ប៊ុន ថន៖ បាទ។

មាស វឿន៖ អាហ្នឹងគេជាអ្នកដឹកនាំធំៗគេរៀបចំយ៉ាងណាយើងមិនដឹងទេ។

ប៊ុន ថន៖ ចឹងគេដកអ៊ំមកខាងណាវិញ?

មាស វឿន៖ ខ្ញុំដកមកខាងបែកចាន ដល់ហើយគេបញ្ជូនខ្ញុំទៅខាងកំពតវិញ ខ្ញុំគេឲ្យទៅការពារផ្លូវរថភ្លើង កាលហ្នឹងនៅកំពតកំពង់ត្រាចវិញ?

ប៊ុន ថន៖ ចឹងកាលអ៊ំដកទៅហ្នឹងប្រជាជនគេជម្លៀសហើយនៅ?

មាស វឿន៖ ប្រជាជនកាលហ្នឹងគេកំពង់តែជម្លៀស ហើយខ្ញុំគេដកចេញទៅការពារផ្លូវរទេះភ្លើងកំពង់ត្រាច ខ្ញុំមិនបានដឹងច្បាស់ដែលកន្លែងហ្នឹង គេមិនឲ្យយើងនៅភ្នំពេញទេ ទាហានគេមិនឲ្យនៅភ្នំពេញទេ។

ប៊ុន ថន៖ ចឹងគេមានណែនាំចរាចរណ៍អីទេ?

មាស វឿន៖ គេណែនាំឲ្យយើងធ្វើស្រែ អត់មានពីណាណែនាំទេ កាលហ្នឹងតា ម៉ុកឲ្យខ្ញុំធ្វើស្រែ គាត់ប្រាប់ត្រង់ចឹង ខ្ញុំច្បាំងចង់សាប់ឲ្យខ្ញុំធ្វើស្រែ ខ្ញុំនឹកចឹងបាក់ទឹកចិត្តដែរ ដល់ហើយខ្ញុំធ្វើខាងកំពតហើយដល់ឆ្នាំ៧៥គេឲ្យខ្ញុំទៅកំពត ដល់បាន៣ខែគេឲ្យខ្ញុំមកនៅវាលវិញ នៅវាល វិញបានតែពីរខែគេឲ្យខ្ញុំមកនៅកោះកុង កោះកុងឆ្នាំ៧៥ដើមឆ្នាំ៧៦ខ្ញុំនៅកោះកុងរហូត ដល់យួនវ៉ៃ។

ប៊ុន ថន៖ ចឹងអ៊ំនៅជាមួយសមមិត្តសឿងរហូតឬមួយយ៉ាងម៉េច?

មាស វឿន៖ បាទ!ខ្ញុំនៅជាមួយសមមិត្តសឿនរហូត ខ្ញុំទៅនៅកោះកុងហ្នឹងបានបីឆ្នាំ យួនវ៉ៃព្រំដែនហើយ កាលហ្នឹងប៉ុល ពតគាត់ផ្លាស់ខ្ញុំឲ្យទៅព្រះវិហា

ខ្ញុំទៅព្រះវិហាកាលឆ្នាំ៧៨ខែ៨ហ្នឹង ឯង គាត់ឲ្យខ្ញុំទៅខាងព្រះវិហាហ្នឹង ពេលហ្នឹងដែលគាត់ឲ្យខ្ញុំទៅ កាលហ្នឹងគេកំពង់តែចាប់ ប្រជាជនកាន់តែច្រើន ខ្ញុំមិនចង់ទៅទេ ព្រោះខ្លាចរឿងគេចាប់ហ្នឹង ខ្លាចក្រែងគេបូកសរុប ទាំងខ្ញុំទៀត កាលហ្នឹងខ្ញុំចង់ប្រកែក តែប៉ុល ពតប្រាប់ខ្ញុំថា បើបក្សបញ្ជាឲ្យទៅយើងត្រូវតែទៅតាមសំណូមពរគេ តាមចិត្តខ្ញុំ ខ្ញុំមិនចង់ទៅទេ ខេត្តព្រះវិហាគេចាប់ណាស់ ចាប់ឡើងខ្ញុំទៅគេបាញ់ខ្ញុំទៀត តែខ្ញុំមិនមានគ្រោះថ្នាក់អីចេះតែរួចខ្លួនរហូត ។

ប៊ុន ថន: ចឹងប៉ុល ពតបញ្ជាមកអីផ្ទាល់?

មាស រឿន: ហ្នឹងហើយ មុនហ្នឹងទៅហ្នឹងគាត់ហៅខ្ញុំពីកោះកុងមក មកភ្នំពេញហើយទៅជួបគាត់នៅក្នុងវត្តខណ្ឌាឡោមហ្នឹង គាត់បង្រៀនប្រហែលជាបីម៉ោង គេថាឥឡូវហ្នឹងយួនវ៉ៃយើងដល់ព្រំដែនហើយ វ៉ៃមកដល់ស្នួល ក្រចេះហើយ ហើយយួនកំពង់តែធ្វើសកម្មភាពវ៉ៃយើងកាន់តែជ្រៅ ចឹងហើយមិត្តឯងត្រូវទៅកាន់នៅព្រះវិហា គេកំពង់តែចាប់ប្រជាជននៅព្រះវិហាកាន់តែច្រើន ដូច្នេះមិត្តឯងត្រូវតែទៅមើលគេចាប់ប្រជាជនយ៉ាងរបៀបម៉េចហើយឲ្យខ្ញុំដោះអ្នកជាប់គុកនៅសៀមរាបផង ។ ចឹងកាលហ្នឹងខ្ញុំខ្លាចចុះគេមិនឲ្យទៅទាំងកងទ័ពណា គេឲ្យទៅតែខ្ញុំនិងកងការពារខ្ញុំមានគ្នាប្រហែលជា២០ប៉ុណ្ណឹង ។

ប៊ុន ថន: បាទ ។

មាស រឿន: ដល់ហើយគាត់ឲ្យខ្ញុំទៅ កាលហ្នឹងខ្ញុំខ្លាចដែរ ខ្ញុំមិនហ៊ានប្រកែកខ្ញុំតាំងចិត្តខ្លួនខ្ញុំទៅចុះ តាំងចិត្តថាជាខ្មោចទៅចុះ ដល់ខ្ញុំទៅដល់ព្រះវិហាហ្នឹងគេធ្វើរដ្ឋប្រហា ធ្វើរដ្ឋប្រហាខៀវ សំផនធ្វើរដ្ឋប្រហាខ្លួន ជា ព្រោះកន្លែងហ្នឹងជាតំបន់ស្វ័យ័ត្តរបស់ខ្លួន ជានិងខៀវ សំផនកន្លែងហ្នឹង ព្រោះកន្លែងហ្នឹងជាតំបន់ខ្ពង់រាប ហើយអំណាចរបស់អង្គការហ្នឹងគេផ្តល់ទៅកន្លែងហ្នឹងច្រើនណាស់ មានម៉ុង ភួយ មានស្ករស មានទឹកដោះគោ មានការស៊ីចុកមានថ្នាំពេទ្យគ្រប់បែបយ៉ាងទាំងអស់ ព្រោះកន្លែងជាតំបន់ដាច់ស្រយ៉ាល តើរបស់ហ្នឹងមានបានទៅដល់ដៃអ្នកស្រុកទេ ។

ប៊ុន ថន: បាទ ។

មាស រឿន: គេឲ្យខ្ញុំទៅស៊ើបការកន្លែងហ្នឹង ពេលដែលខ្ញុំទៅដល់កន្លែងហ្នឹងខ្ញុំក៏មិនដឹងជាភូមិសាស្ត្រនៅណាដែរ ចេះតែមើលតាមផែនទីមើលតាមត្រៃវិស័យហ្នឹងទៅ ពេលហ្នឹងកន្លែងមន្ទីររបស់ខេត្ត គេរើរុះអស់ហើយ ហើយគេត្រៀមបាញ់ខ្ញុំទៀត ចឹងខ្ញុំចេះតែរៀបចំទៅ កន្លែងហ្នឹងមានការចាប់ចងហើយអត់បាយទៀត នៅពេលហ្នឹងស៊ីក្តួចអីហ្នឹង

ខ្ញុំគិតថាពេលហ្នឹងគេ ចោទខ្ញុំជាខ្មាំងទៀតហើយ ខ្ញុំមិនដឹងជាទៅរកបាយណា បើខ្ញុំផ្លាស់ពីនេះទៅនោះ ពីចុង ប្រទេសទៅចុងប្រទេសខាងនោះទៀត ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយខ្ញុំចេះតែរស់នៅជាមួយអ្នកស្រុកចិនទៅ ខ្ញុំទៅដល់ឃើញកន្លែងមិនមានបាយទឹក ទីមួយខ្វះបាយទឹកមិនមានទេ ទីពីរគឺចាប់ប្រជាជនសូម្បីប្រជាជននៅកន្លែងនោះឮសូរឡានមិនបានផង កាលហ្នឹងខ្ញុំនៅវាំង ខ្ញុំឈរនៅវាំងខ្ញុំសួរអ្នកស្រុកថា កន្លែងវិទ្យាល័យគ្រូគេ ទៅណា គេថាជម្លៀសចេញអស់ហើយ ចឹងផ្ទះធំៗផ្ទះចិនទៅណា? គេថាជម្លៀសចេញអស់ហើយ ខ្ញុំដើរស្រាវជ្រាវទាំងអស់ ស្រាវជ្រាវខ្ញុំរកឃើញឈ្មោះ ព្រំ ស៊ូមួយ គាត់អង្គុតដៃនេះ កាលហ្នឹងគាត់បង្ហាត់នៅសាលាហ្នឹង ខ្ញុំចេះតែស្រាវជ្រាវរកទៀតទៅ ឃើញខ្ញុំចេះ ដើរប្រមែប្រមូលគៀងគរពីកន្លែងព្រៃមកវិញ មកនៅជាមួយសហករណ៍គេ មកកុំទៅនៅព្រៃដាំដំឡូងអីចឹងទៀត ខ្ញុំចេះតែប្រាប់សហករណ៍ចឹងទៅ ខ្ញុំមិនដឹងពីណាជាសហករណ៍អីខ្ញុំមិនសូវដឹងទេ ខ្ញុំថាពូណាទទួលខុសត្រូវកន្លែងនេះដែលធំជាងគេឲ្យគាត់មករស់នៅកន្លែងនេះផង ។ បានគេដឹងពីកន្លែងហ្នឹងបានបងប្អូនម្នាក់ ប្រហែលជាគេជម្លៀសពីភ្នំពេញមកនៅកន្លែងនេះ ឥឡូវគាត់ទៅនៅអាមេរិចគាត់ស្គាល់ខ្ញុំដែរ ខ្ញុំនៅកន្លែងហ្នឹងគេរករឿងខ្ញុំដែលតែគេធ្វើអីខ្ញុំមិនកើត ខ្ញុំចេះតែទ្រាំរហូតទៅ ហើយគាត់ប្រាប់ខ្ញុំថាមិត្តឯងមិនចាំបាច់ធ្វើអីឲ្យគាត់ទេ ធ្វើរបៀបឆ្នាំ៧០បានហើយ ឲ្យគាត់ធ្វើស្រែធម្មតាធ្វើឲ្យបានហូបមិនចាំបាច់ប្រព័ន្ធប្រឡាយដូចគេទេ គាត់ធ្វើម៉េចបានហូបធ្វើទៅ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់ប្រាប់ចឹង ។

ប៊ុន ថនៈ ចឹងមានបញ្ហាចេញមកចឹង?

មាស វឿនៈ បញ្ហាចេញមកពីប៉ុល ពតផ្ទាល់ គាត់ប្រាប់ខ្ញុំកាលនៅវត្តខណ្ឌឡោម ខ្ញុំមិនចាំថ្ងៃតែដឹងថាខែ៨គាត់ថាទីមួយឲ្យគាត់ធ្វើស្រែធម្មតា ទី២យើងរៀបម៉ាស៊ីនធ្វើផ្ទះឲ្យគាត់នៅបានហើយពីរមុនហ្នឹងបានហើយគាត់ប្រាប់តែប៉ុណ្ណឹងឯង ពេលដែលធ្វើចឹងហើយមានបានប៉ុន្មានខែ មិនបានប៉ុន្មានខែផងហ្នឹង ខ្ញុំទៅបានតែបួនខែប៉ុណ្ណឹងឯង យួនត្រូវវៃលុកចូលភ្នំពេញបាន ខ្ញុំមានបានធ្វើអី បានធ្វើផ្ទះប្រហែលជា៣០ខ្នងប៉ុណ្ណឹងឯង ។

ប៊ុន ថនៈ ចឹងកាលយួនវៃចូលហ្នឹងអ៊ំនៅទីនោះ?

មាស វឿនៈ បាទ!វៃចូលទៅខ្ញុំនៅតាមហ្នឹងមក មកតាមភ្នំដងរែកចឹងមក មកតាមបន្ទាយឆ្មារចឹងមក ចេញទៅដល់ម៉ាឡៃ ចេញរហូតទៅដល់ឡៃមចឹងទៅ ខ្ញុំដើររយៈពេលបួនខែខ្ញុំដើរតែរហូតចឹងមក ។

ប៊ុន ថនៈ ចឹងអ៊ីមានដឹងថាសមមិត្តសឿងទៅណាដែរ?

មាស វឿនៈ អត់ កាលហ្នឹងគាត់ស្លាប់ហើយ បងសឿងកាលដែលយួនវៃចូលភ្នំពេញហ្នឹងគាត់នៅខាងសៀមរាប គាត់ឲ្យខ្ញុំទៅនៅព្រះវិហារគាត់ទៅនៅសៀមរាប ក្រុមគាត់ហ្នឹងជម្លៀសមកតាម គោកមនចឹងមក តែខ្ញុំនៅខាងព្រះវិហារតែម្នាក់ឯង គាត់មកតាមហ្នឹងមិនដឹងជាយ៉ាងម៉េច ពួកស្អប់គាត់ឬយ៉ាងម៉េច គេបាញ់សម្លាប់គាត់នៅលើឡាន ឆេះទាំងឡានទៀត មកឆេះ នៅម្តុំគួហ្នឹងឯង បាញ់ទាំងពេទ្យអីហ្នឹងបាញ់ងាប់ទាំងអស់ហើយនៅតែខ្ញុំម្នាក់ឯងនៅព្រះ វិហារហ្នឹង ខ្ញុំចេះតែដើរមកកងទ័ពត្រង់ណាក៏គេស្រឡាញ់ខ្ញុំ កាលហ្នឹងគេមិនចង់ឲ្យបែកជង តែខ្ញុំចេះតែមកៗ ដាច់ចិត្តមកៗព្រោះមិនមែនស្រុកខ្ញុំដែរ ។

ប៊ុន ថនៈ ចឹងកាលពូទៅធ្វើថ្នលរទេះភ្លើងនៅកំពតហ្នឹងពូនៅបានយូរទេ?

មាស វឿនៈ ខ្ញុំនៅបានបីខែ នៅកំពតនៅខាងកំពង់ត្រាច ដល់ក្រោយមកគេផ្លាស់ខ្ញុំមកនៅខាងវាលរិញ ជិតផ្លូវកំពង់សោមនេះ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ខ្ញុំនៅខាងវាលរិញហ្នឹង នៅបានប្រហែលជាមួយខែ ខ្ញុំមកនៅស្រែអំបិលកោះកុងមិនមែនស្រែអំបិលកំពតទេ ខ្ញុំនៅហ្នឹងបានប្រហែលមួយដែលបានខ្ញុំមកនៅខាងព្រំដែនថៃរហូត ។

ប៊ុន ថនៈ តែអ៊ីនៅកងពលជាមួយសមមិត្តសឿង?

មាស វឿនៈ បាទ ។

ប៊ុន ថនៈ កាលហ្នឹងមកគ្នាច្រើនទេ?

មាស វឿនៈ កាលមកកោះកុងមកគ្នាប្រហែលជា៣០០០នាក់ កាលហ្នឹងនៅព្រំដែនសមុទ្រ ខ្ញុំនៅកោះកុង កោះយ៉ កោះមូល កោះចាំយាមខ្ញុំនៅជាប់ព្រំដែនថៃរហូតបីឆ្នាំ ។

ប៊ុន ថនៈ ចឹងពូទទួលបញ្ជាពីអគ្គសេនាធិការមក?

មាស វឿនៈ ខ្ញុំទទួលពីតា ខៀវ ហៅ សុន សេន ។

ប៊ុន ថនៈ ចឹងមកហ្នឹងការពារព្រំដែនឬយ៉ាងម៉េច?

មាស វឿនៈ មកការពារព្រំដែនរហូត ។

ប៊ុន ថន: ចឹងជាមួយថៃអីមានដែលប៉ះគ្នាទេ?

មាស វឿន: ប៉ះដែរ ប៉ះដាន់មួយអាទិត្យ ។

ប៊ុន ថន: មានមូលហេតុអីបានប៉ះគ្នា?

មាស វឿន: មូលហេតុវាចាប់ត្រីហើយ វាចេះតែឆ្ការដាក់របងលួសហើយវាចាប់ត្រីក្នុងដីយើងចឹងទៅ យើងឃើញវាចូលមកដល់កោះយើងចឹង វាមកស៊ើបការណ៍យើងប៉ះពាល់គ្នាយើងបាញ់មានយន្តហោះទម្លាក់ចឹងដែរ ។

ប៊ុន ថន: តែកាលហ្នឹងមានអ្នករត់ឆ្លងដែនទៅថៃអីទេ?

មាស វឿន: ខាងខ្ញុំអត់មានទេ មានតែច្បាំងគ្នាហើយស្លាប់ កាលរត់ទៅថៃអត់មានទេ តែខាងពាយ័ព្យគេមាន ខាងបាត់ដំបងមាន ខាងកងពលហ្នឹងគេមាន ។

ប៊ុន ថន: ចឹងកាលវៃជាមួយវៀតណាមកាលឆ្នាំ៧០ដាន់ហ្នឹងមានបានទទួលដំណឹងអីទេ?

មាស វឿន: នៅពេលវៀតណាមវៃតិចៗតាមព្រំដែនហ្នឹង ខ្ញុំបានដឹងពីសភាពការណ៍ហ្នឹង កាលហ្នឹងវាវៃយើង យើងក៏វៃវាដែរ ។

ប៊ុន ថន: បាទ ។

មាស វឿន: ដូច្នេះវាវៃយើង យើងក៏វៃវាលដែរ ឧបមាយើងវាវៃយើងនៅខាងព្រំដែនតាកែវ ព្រៃវែង ស្វាយរៀងមកដល់ក្រចេះ ស្នួល មករតនៈគិរី កាលហ្នឹងខាងរតនៈគិរីមិនទាន់វៃទេ វៃតែខាងក្រចេះ ព្រៃវែង ស្វាយរៀង តាកែវអាហ្នឹងគេវៃបន្តិចៗមក នៅពេលដែលវៃ ហ្នឹងខ្ញុំដឹងថាសភាពការណ៍ព្រំដែនមិនស្រួល ហើយកាលហ្នឹងទូតវៀតណាមដាក់ជាភ្នាក់ងារ ទេ វីរៈធារីសម្រាប់តែយកការណ៍ប៉ុណ្ណឹងឯង ។

ប៊ុន ថន: បាទ ។

មាស វឿន: មិនមែនជាអគ្គរាជទូតត្រឹមត្រូវទេ តែសភាពការណ៍ព្រំដែនហ្នឹងវាមានដួរចឹងរហូតដល់វាដល់ពេលវាលេងខ្លាំងតាមស្នួល ខាងកំពង់ចាមហ្នឹងបានវាលេងខ្លាំងយើងកាលហ្នឹងក៏បញ្ជូន កំលាំងទៅដែរ កំលាំងខ្ញុំនៅខាងលិចបញ្ជូនទៅឲ្យទាំងអស់ ខ្ញុំនៅសល់តែ៤០០ទៅ៥០០ នាក់ប៉ុណ្ណឹងឯង ដូច្នេះបញ្ជូនទៅវៃរហូតដល់តែនិញ ។

ប៊ុន ថន: ចឹងមានកំលាំងអីចូលទៅវៃ?

មាស វឿនៈ ខ្ញុំឲ្យកំលាំងខ្ញុំចូលទៅ តែខ្ញុំនៅខាងលិចនេះនៅឡើយទេ តែកំលាំងខ្ញុំឲ្យទៅខាងនោះហើយ ដល់វៃគ្នាខ្លាំងចឹងបានជាគេដកខ្ញុំឲ្យទៅខាងព្រះវិហាចឹងឯង ។

ប៊ុន ថនៈ ចឹងកាលដែលហៅអ៊ំទៅប្រជុំអីនោះហ្នឹងមុនទៅព្រះវិហា?

មាស វឿនៈ ហ្នឹងពេលដែលខ្ញុំទៅហើយហ្នឹង ខ្ញុំឡើងទៅប្រជុំទៅបណ្ដោយ ។

ប៊ុន ថនៈ ចឹងពេលអ៊ំចេញពីភ្នំពេញកាលឆ្នាំ៧៥ហ្នឹង អ៊ំមិនបានទៅភ្នំពេញវិញទេ?

មាស វឿនៈ អត់ទេ ដាច់រហូតបានឈ្នះម្ដងកាលឆ្នាំ៧៥ដែលរំដោះភ្នំពេញហ្នឹង ដល់ហើយមិនដែលបានចូលទៀតទេ ។

ប៊ុន ថនៈ ចឹងអ៊ំមានដែលជួបមិត្តភក្តិដូចជាចេង អនអីមានដែលបានជួបទេ?

មាស វឿនៈ មិនដែលបានជួបទេ ដាច់គ្នាហើយគេមានមុខងារការងារគេធំៗ ខ្ញុំមិនបានជួបរហូតចេង អនក៏មិនបានជួបទៀវ សំផនក៏មិនបានជួប ហ៊ូ នឹមក៏មិនបានជួបនិយាយរួមកងពលខ្លះមិនបានជួបគ្នារហូត រហូតដល់ថ្ងៃនេះមិនដែលបានជួប ។

ប៊ុន ថនៈ ចឹងប្រធានកងពលអ៊ំមានស្គាល់ទេ ដូចជាឈូក ច័ន្ទចក្រីអីហ្នឹង?

មាស វឿនៈ បានជួបម្ដង ចក្រីជួប ឈូកជួប អីទេកូនប្រសាតាម៉ុកនេះ មាស មុតជួប ម៉េតជួបខ្ញុំចាស់ហើយខ្ញុំភ្លេចខ្លះហើយ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហ្នឹងសុទ្ធមិត្តភក្តិខ្ញុំហើយ កាលដែលជួបទាំងអស់គ្នាហ្នឹងមានពួកជើងគោក ជើងទឹក ជើងអាកាស ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ព្រោះពេលដែលឈ្នះភ្នំពេញហ្នឹងគេមិនរៀបចំកងទ័ពជើងទឹកជើងគោកជើងអាកាស នៅពេលហ្នឹងហើយដែលយើងបានជួបគ្នានោះ ដល់ពេលបែកហើយរៀបចំតាមមុខសញ្ញាអាហ្នឹងយើងមិនបានចូលទេ ។

ប៊ុន ថនៈ ចឹងអ៊ំមានបានចូលរួមនៅស្តាតទេ?

មាស វឿនៈ ចូលរួមបុណ្យគេនោះណាស់ ។

ប៊ុន ថនៈ ចឹងអ៊ំកាលហ្នឹងមានដឹងថាមានព្រឹត្តិការណ៍ចង់សម្លាប់អីដែរ ដែលថាមានឆែកកាំភ្លើងអី?

មាស វឿនៈ កាលហ្នឹងគេមិនទាន់មានសម្លាប់អីទេ ។

ប៊ុន ថនៈ តែមានគេឆែកកាំភ្លើងទេ?

មាស វឿនៈ អើយមានគេឆែក របៀបគេឆែកដូចថានេះជាទីលានស្តាតអឺចឹងទៅ នៅពេលយើងចូល គេនៅចាំក្លោងទ្វារចាំឆែកយើង គេឆែកតាំងពីប៉ិច សៀវភៅសក់ក្បាលដល់ចុងជើងយើង អត់មានអីគេឲ្យចូលទៅ បើពីណាមានប៉ិចសូឡិចគេដកទុកសិន មកវិញបានគេឲ្យយើង តែ កាំភ្លើងដូចជាមិនមានទេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដូចជាឆែកមិនប៉ះទេ គេមិនយកទៅទេ ។

ប៊ុន ថនៈ តែកាលហ្នឹងខ្ញុំដឹងថាមានឆែកប៉ះគ្រាប់កាំភ្លើងអីដែរ?

មាស វឿនៈ ចឹង!មាននៅពេលដែលគេមិនធ្វើបុណ្យអីដឹង ក្រែងក្រោយមកទៀតម៉េចដឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ នៅពេលដែលគេធ្វើបុណ្យហ្នឹងមិនមានទេ ឆែកមិនមានប៉ះទេ ពីព្រោះដំបូងឡើយមនុស្ស កំពង់តែចង់បានអំណាច ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដល់គេចង់បានអំណាចគេគោរព គេគោរពវិន័យ គោរពច្បាប់' គោរពបទបញ្ជាចឹងណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ តែដល់ក្រោយមកទៀតយើងមិនបានដឹងទេ តែឲ្យតែចូលទៅគេឆែកចឹងហើយ តាំងពីខោ អាវជើងដៃចឹងមក ។

ប៊ុន ថនៈ ចឹងអ៊ីកាលហ្នឹងបានចូលរួមហ្នឹងដែរ?

មាស វឿនៈ បាទ!ខ្ញុំបានចូលរួមនៅហ្នឹងតើ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងជួបជុំគ្នាទាំងអស់?

មាស វឿនៈ ហ្នឹងហើយជួបជុំគ្នាទាំងអស់ ។

ប៊ុន ថនៈ ចឹងក្រោយពីហ្នឹងមកអ៊ីមានបានចូលរួមផ្សេងៗទៀតដែលអី?

មាស វឿនៈ អត់មានទេ មានតែប្រជុំកងពលមាន ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ក្រោយពីយើងធ្វើបុណ្យធំៗហ្នឹងមកមានបុណ្យជ័យជំនះឯករាជ្យចឹងមក ក្រោយមកគេ មានប្រជុំដែរ គេប្រជុំរៀនសូត្រពីយុទ្ធវិធី ពីរឿងការកសាងប្រទេសអីចឹងបុកសាងស្នូរ ដឹកនាំអីចឹងណាស់ ។

ប៊ុន ថន:	បាទ ។

មាស វឿន:	អាហ្នឹងក៏គេផែកដូចគ្នា	តែខ្ញុំដូចជាមិនបានឲ្យគេផែកខ្ញុំដូចជាមិនបានដាក់យកទៅផង យើង ត្រឹមត្រូវមិនដឹងជាដាក់យកធ្វើអីផង តែមានកន្លែងគេផែកឃើញខ្ញុំមិនបានដឹង ។

ប៊ុន ថន:	បាទ ។

មាស វឿន:	ខ្ញុំមិនបានតាមដានផងអាហ្នឹងជារឿងរបស់គេ ព្រោះអាហ្នឹងជារឿងរបស់គេជាអ្នកឃាមកាម ។

ប៊ុន ថន:	បាទ ។

មាស វឿន:	យើងភ្លៀវចេះតែចូល ៗ ចឹងទៅ ។

ប៊ុន ថន:	ចឹងក្រោយ ៗ ពូមានដែលជួបអ្នកទាំងហ្នឹងទេ?

មាស វឿន:	ក្រោយសព្វថ្ងៃហ្នឹង ។

ប៊ុន ថន:	ក្រោយកាលសម័យហ្នឹង?

មាស វឿន:	កាលសម័យហ្នឹងអ្នកដឹកនាំធំ ៗ មិនដែលបានជួបទៀតទេ ជួបអាចបានត្រឹមភូមិភាគខ្លះឬអ្នកដឹកនាំជាន់ខ្ពស់អាចជួបបានប្រហែលជាមួយខែអី ។

ប៊ុន ថន:	បាទ ។

មាស វឿន:	នៅពេលដែលគេមកបង្រៀនតាមភូមិភាគអីហ្នឹង ព្រោះខាងកងពលទៅរួមប្រជុំហ្នឹងគេដែរ ដូចថាគេប្រជុំភូមិភាគណា ដូចថាប្រជុំភូមិភាគបញ្ញើមចឹង មានគណៈកម្មាធិការភូមិភាគនិយាយឲ្យខ្ញុំ ។

ប៊ុន ថន:	បាទ ។

មាស វឿន:	មានគណៈកម្មការអចិន្ត្រៃយ៍ភូមិភាគ មានគណៈកម្មការអចិន្ត្រៃយ៍មជ្ឈឹមមានម្នាក់ឬពីរគេអាចចូលរួម ។

ប៊ុន ថន:	កាលហ្នឹងនៅពីណាគណៈកម្មការភូមិភាគ?

មាស វឿន:	កាលហ្នឹងនៅ តា ស៊ី ជូ ចេតហៅស៊ី ហើយមានរងភូមិភាគចឹងទៅមានប្រធានកងពល តា សឿងចឹងទៅ ចឹងគណៈកម្មការខាងមជ្ឈឹមមានពីណា មានប៉ុល ពតឬនួន ជាចឹងទៅ ។

ប៊ុន ថន:	ចឹងតា ខៀវ គាត់មានដែលមកទេ?

មាស វឿន:	តា ខៀវ មិនដែលមកទេ ។

ប៊ុន ថន:	ចឹងពូបានជួបនៅពេលប្រជុំធំ ៗ ទេ?

មាស វឿនៈ បាទ!បានជួបនៅពេលប្រជុំធំៗទេ ដូចជាប្រជុំគណៈកងពលអី នៅពេលខ្លះខ្ញុំមិនបានញឹកញាប់ដែរ ព្រោះខ្ញុំនៅឆ្ងាយពេលខ្លះគេប្រជុំភូមិភាគ គណៈអចិន្ត្រៃយ៍ភូមិភាគទៅ ធម្មតាគេត្រូវហៅគណៈកម្មការភូមិភាគ គេហៅតំបន់ ដូចរាល់ថ្ងៃយើងហៅថាចៅហ្វាយខេត្តរាល់ថ្ងៃ។

ប៊ុន ថនៈ បាទ។

មាស វឿនៈ គេត្រូវហៅស្រុកមិនចឹង ហើយគេត្រូវហៅខាងយោធាទៅស្តាប់ដងមិនចឹង។

ប៊ុន ថនៈ បាទ។

មាស វឿនៈ អាហ្នឹងបានខ្ញុំបានចូលរួម បើសិនជាប្រជុំសម្ងាត់ខ្ញុំមិនបានចូលរួមទេ។

ប៊ុន ថនៈ ចឹងបានចូលរួមជាមួយដូ ចេតហ្នឹងក្រោយមកមានឃើញគាត់ចូលរួមប្រជុំទៀតទេ?

មាស វឿនៈ ខ្ញុំមិនបានចូលរួមទៀតទេ ព្រោះសង្គ្រាមវាកាន់តែឡើងទៀតហើយខ្ញុំឈប់ហើយមិនបាន ចូលរួមប្រជុំទេ។

ប៊ុន ថនៈ បាទ។

មាស វឿនៈ ព្រោះកាលហ្នឹងសភាពការណ៍ព្រំដែនវាមិនស្រួល។

ប៊ុន ថនៈ តែពូមានដែលឃើញគាត់ទៀតទេ?

មាស វឿនៈ មិនដែលឃើញទេ ខ្ញុំខានឃើញគាត់ក្រោយឆ្នាំ៧៦ និយាយមែនទែនក្រោយពីបាត់គាត់ខ្ញុំមិនដែលបានចូលរួមប្រជុំទៀត។

ប៊ុន ថនៈ ចឹងពូមានឆ្ងល់ថាគាត់បាត់ទៅណាដែរ?

មាស វឿនៈ ខ្ញុំដឹងថាមានរឿងហេតុហើយ ខ្ញុំដឹងតាមកងពលខ្ញុំប្រាប់ ព្រោះកងពលខ្ញុំជាសមាជិករបស់ភូមិភាគដែរណាស់។

ប៊ុន ថនៈ បាទ។

មាស វឿនៈ ម្យ៉ាងគាត់មានប្រត្តិកម្មទំនាស់ជាមួយប៉ុល ពតហ្នឹងប្តូទំនាស់ជាមួយពីណាខ្ញុំមិនបានដឹងដែរតែវាមានកិច្ចការផ្ទៃរចឹង។

ប៊ុន ថនៈ បាទ។

មាស វឿនៈ តែកិច្ចការផ្ទៃរគេអ្នកធំគេមិនឲ្យយើងដឹងច្បាស់ទេ គ្រាន់តែបានដឹងតាមគ្នា។

ប៊ុន ថនៈ ចឹងពូដឹងតាមប្រធានកងពលពូ?

មាស វឿនៈ បាទ។

ប៊ុន ថនៈ ចឹងកាលហ្នឹងសមមិត្តសឿងនៅដដែល?

មាស វឿនៈ សឿនគាត់នៅ ។

ប៊ុន ថនៈ ចឹងពូមានដឹងថាដូ បេតគេចាប់គាត់?

មាស វឿនៈ រឿងចាប់គេមិនដែលប្រាប់យើងទេ ។

ប៊ុន ថនៈ ចឹងពូអាចដឹងថា ដូ បេតមានកំហុសយ៉ាងម៉េចដែរ?

មាស វឿនៈ ខ្ញុំមិនបានដឹងថាគាត់មានកំហុសបែបណាទេ យើងមិនបានដឹងច្បាស់ទេ យើងដឹងតាមមិត្តភក្តិឱ្យបគ្នាទេ ជំនាន់ហ្នឹងមានបាននិយាយដូចយើងចេះណា សុទ្ធឱ្យបគ្នាសក់អាណាក្បាលអាហ្នឹងហើយ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹងគេថា ខាងតា ស៊ីហ្នឹងគាត់មានក្រុមគាត់ប្រុងធ្វើរដ្ឋប្រហារទម្លាក់អ្នកដឹកនាំដែរ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ជាមួយនិងសោ ភឹម កង ចាប កាលហ្នឹងភូមិភាគទាំងអស់គេត្រូវគ្នាបណ្តោយកាលហ្នឹង គេចង់រំលំបក្សដឹកនាំ គេចង់រំលំប៉ុល ពតហ្នឹងណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ យើងនិយាយឲ្យខ្ចីចឹងទៅ កាលហ្នឹងរួមជាមួយ ចេង អននោះដងក្រសួងខាងសេដ្ឋកិច្ចរដ្ឋដងក្នុងហ្នឹងវាមានទំនាក់ទំនងគ្នា ដល់មានត្រូវគ្នាចឹងមានន័យថាគេចង់ផ្តួលយកអំណាចរបៀបចង់បានអំណាចនោះ វាពិបាកនិយាយដែរ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយ សោ ភឹមគេថាគាត់មែនទែនគាត់មានទំនាក់ទំនងជាមួយវៀតណាម វៀតណាមហ្នឹងយកស្រើមកឲ្យសោ ភឹម ហើយព្រំដែននៅបូព៌ាហ្នឹងមានបន្ទាយមួយយន្តហោះរបស់វៀតណាមសម្រាប់ដឹកយកស្រើមកឲ្យធ្វើការងារជាមួយសោ ភឹម ដូច្នេះវាមានទំនាក់ទំនងគ្នារបៀបចឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយកាលដែលទំនាស់គ្នាបាត់ វ៉ន វ៉េត ទំនាស់រឿងចេះមួយនៅពេលដែលវៀតណាម វ៉ៃរុកចូលមកស្រុកខ្មែរកាន់តែជ្រៅៗទៅ វ៉ន វ៉េតគាត់ទទួលឧបករណ៍សឹកហ្នឹងដូចជារថ ក្រោះគាត់រ៉ាប់រងដូចជាក្រសួងការពារជាតិចឹង គាត់ទទួលបានរថក្រោះនិងកាំភ្លើងធំហ្នឹង

គាត់ទទួលបានរៀបចំតាមបញ្ជារបស់សុន សេន គាត់បញ្ជាគណៈកម្មការអចិន្ត្រៃយ៍របស់មជ្ឈិមបក្សដែរ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ នៅពេលហ្នឹង ប៉ុល ពត បញ្ជាឲ្យវន វេតយករថក្រោះនិងកាំភ្លើងធំទៅតាំងទៅតាមព្រំដែនវៃទៅ ដល់នេះឮថា វន វេតហ្នឹងមានទំនាស់ជាមួយប៉ុល ពត តែការពិតខ្ញុំមិនបានឮផ្ទាល់ទេ ខ្ញុំបានឮតាមគ្នាឯងចឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ វន វេតគាត់និយាយជាមួយ ប៉ុល ពតថា មិនបាច់យកទៅទេ យួនវៃមិនបានគ្រប់គ្នាផង មិនបាច់យករថក្រោះកាំភ្លើងធំទៅទេ វន វេតគាត់និយាយចឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់ថាយួនវៃមិនបានគ្រប់គ្នាផង ចឹងក្នុងការទំនាស់ហ្នឹងមានបញ្ហាត្រង់ហ្នឹងមួយ តែប៉ុល ពតគាត់ចង់ឲ្យយករថក្រោះកាំភ្លើងធំទៅរៀបចំឲ្យហើយទៅ តែវន វេតគាត់ទំនាស់ វន វេតថា យួនវៃមិនបានគ្រប់គ្នាផងមិនចាំបាច់យកទៅទេ និយាយចឹងមានន័យថាទំនាស់ហើយមិនថាចឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ចឹងយើងស្ដាប់យើងដឹងថាមានទំនាស់គ្នាហើយ ចឹងនៅពេលហ្នឹងហើយដែលវន វេតបាត់ខ្លួនហ្នឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ មិនចឹង ។

ប៊ុន ថនៈ ចឹងពូបានទទួលដំណឹងហ្នឹងដេរ?

មាស វឿនៈ បាទ! ចឹងមានមិត្តភក្តិខ្ញុំ កាលហ្នឹងមានទូរស័ព្ទឯណាដូចឥឡូវ តែយើងជួបមិត្តភក្តិទៅយើងដឹង កាលពីដើមយើងមានទូរស័ព្ទអា“វេសេវង់សែង”នោះណាស់ របស់អាមេរិចកាំង យើងអាចនិយាយគ្នាសម្ងាត់បានតិចៗ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ បានមួយមាត់ពីរមាត់ចឹងយើងបិតទៅ ។

ប៊ុន ថនៈ ចឹងកុយ ធួនគេចាប់ខ្លួនគាត់ពូមានដឹងរឿងទេ?

មាស វឿន៖ កុយ ធួនខ្ញុំដូចជាមិនបានស្គាល់គាត់ផង តែបើនង សួនអីខ្ញុំស្គាល់ តែកុយ ធួនខ្ញុំដូចជាមិន ច្បាស់ ខ្ញុំដូចជាមិនមានទំនាក់ទំនងគ្នាចឹងដូចជាមិនបានស្គាល់ច្បាស់ បើក្រៅពីហ្នឹងដូចជាច្បាស់ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ មើលខ្ញុំមិនបានស្គាល់ច្បាស់ដូចជាសោ ភីមមួយ កង ចាបមួយ តែមិនដឹងច្បាស់ទេតែឮឈ្មោះ រស់ ញឹមក៏មិនច្បាស់ដែរ តែដឹងថាគាត់ធ្វើធំៗតែមិនបានស្គាល់ច្បាស់ទេ បើក្រៅពីហ្នឹងដូច ជា ហ៊ូ យន់ ហ៊ូ នឹម ខៀវ សំផន ចេង អនហ្នឹងសុទ្ធតែដើរវង្វេងព្រៃជាមួយគ្នាហើយ បើចេង អនស្លាប់រស់ជាមួយគ្នា នង សួនតែមិនដឹងឈ្មោះដើមឈ្មោះអីទេ ព្រោះឈ្មោះបដិវត្តន៍ប្រែច្រើន ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ តា ស៊ី តា ម៉ុកហ្នឹងដឹងតែមុខនិងមានបញ្ហាជនមួយចំនួនដែលស្លាប់ដូចជា ទីវ អុលគាត់ មកតស៊ូដែល តែគាត់គ្រុនចាញ់ស្លាប់ ។

ប៊ុន ថន៖ ចឹងមានដឹងទេ ថាហ៊ូ យន់ឬហ៊ូ នឹមទេ ពីរនាក់ហ្នឹងមានម្នាក់ស្លាប់មុន៧៥មានដឹងទេ?

មាស វឿន៖ ហ៊ូ នឹម ។

ប៊ុន ថន៖ ចឹងមានមូលហេតុអីបានគាត់បាត់ខ្លួន?

មាស វឿន៖ តាមពិត ហ៊ូ នឹមខ្ញុំជាអ្នកការពារគាត់ទាំងអស់ ខ្ញុំការពារគាត់តាំងពីអាយុ១៨ ខ្ញុំការពារគាត់រហូត ខ្ញុំមែនទែនទៅដូចជាសិស្សគាត់ទៅចុះ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ ខ្ញុំការពារគាត់មានជីវិតរហូតដល់បានចូលក្រុងភ្នំពេញ តាមពិត ហ៊ូ នឹមគាត់កាន់ក្រសួងពត៌មាន ខាងឃោសនាការពត៌មាន ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ ហើយគាត់គ្រប់គ្រងទាំងអស់ ដូច្នេះគាត់អត់មានទំនាស់អ៊ីទេ ខ្ញុំឮតាមមិត្តភក្តិខ្ញុំហើយខ្ញុំក៏មិនបានជួបដែរ តែយើងបានដឹងដំណឹងខ្វះៗពីមិត្តភក្តិគាត់មានប្រត្តិកម្មមួយគាត់ខុសសីលធម៌ជាមួយក្រុមវិទ្យុជាតិហ្នឹងណាស់ ហ្នឹងដំណឹងដែលគេប្រាប់ខ្ញុំចឹង ខុសសីលធម៌បើយើងពិចារណាមើលទៅវាមិនអាចគ្រោះថ្នាក់ដល់ប៉ុណ្ណឹងទេ

បើគាត់មានរឿងអ៊ីទៀតយើង មិនដឹង តែកូនក្រមុំគាត់ខ្ញុំក៏ស្គាល់គាត់មានកូនក្រមុំពីរនាក់ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ កាលឆ្នាំ៧៥ ហើយ

កប៉ាល់ម៉ាយ៉ាហ្គេអាមេរិចកាំងចូលមកោះពោវៃកោះតាងកំពង់សោម

គាត់នៅផ្សាយគាត់នៅការពារហ្នឹង តែគេនិយាយប្រាប់ខ្ញុំតែរឿងមួយទេ គឺសីលធម៌

មិន ដឹងជាសីលធម៌ប៉ុន្មាននាក់ខ្ញុំមិនបានដឹងដែរ

ពីព្រោះគាត់នៅកន្លែងស្រួលហើយនារីកាល នោះស្អាតៗដែលណា ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ ខ្ញុំមិនបានដឹងដែរ ។

ប៊ុន ថន៖ កាលហ្នឹងគាត់គ្រប់គ្រងខាងសិល្បៈអីដែរ?

មាស វឿន៖ ហ្នឹងហើយ ខាងសិល្បៈទាំងអស់នៅលើគាត់ ។

ប៊ុន ថន៖ ចឹងកាលហ្នឹងពូនៅជាមួយគាត់នៅស្ទឹងមានជ័យហ្នឹង?

មាស វឿន៖ អត់ទេ កាលនៅសម្ងាត់ជាមួយហ្នឹងខ្ញុំ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ ដល់ឈ្នះហើយខ្ញុំមានបាននៅឯណា ខ្ញុំនៅកោះកុងឯនោះ ខ្ញុំជាទាហានម៉េចបានទៅនៅជាមួយហ្នឹងគេ ។

ប៊ុន ថន៖ កាលហ្នឹងគាត់នៅស្ទឹងមានជ័យជាមួយប្រពន្ធកូនគាត់ ។

មាស វឿន៖ ហ្ហូ នឹម?

ប៊ុន ថន៖ បាទ ។

មាស វឿន៖ កាលហ្នឹងខ្ញុំមិនបានស្គាល់កន្លែងគាត់ទេ តែខ្ញុំគ្រាន់តែបានដឹងថា ក្រោយពីឈ្នះហើយគាត់បានទទួលតំណែងហ្នឹងឯង ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ តំណែងវិទ្យុជាតិសារពត៌មានក្រុមគាត់ទាំងអស់វាច្រើនក្រុម ខ្ញុំនៅសមុទ្រនោះខ្ញុំមិនបាននៅភ្នំពេញទេ មានបានស្គាល់ផ្ទះថ្មណាគេ ។

ប៊ុន ថន៖ ចឹងពូស្និតស្នាលជាមួយគាត់?

មាស វឿន៖ និយាយមិនស្និតស្នាលយ៉ាងម៉េចគាត់ចេញមកព្រៃនោះ ចេញឆ្នាំ៧០មិនសម្ដេចសីហនុគាត់ទោសគាត់ កាលហ្នឹងគាត់មកខ្ញុំការពារគាត់ ។

ប៊ុន ថន៖ បាទ ។

មាស វឿនៈ បើគាត់នៅក្នុងគេមិនដាក់គុកគាត់ កាលនោះគេឲ្យតម្លៃ៤លានរៀន កាត់ក្បាលខៀវ សំដននិង ហ៊ូ នឹម ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹង៤លាន ។

ប៊ុន ថនៈ ពីណាជាអ្នកឲ្យកាត់?

មាស វឿនៈ សម្តេចសីហនុហ្នឹង កាត់ទោស កាត់យកតែក្បាល ។

ប៊ុន ថនៈ ចឹងសម្តេចសីហនុប្រកាស?

មាស វឿនៈ អើយ!សម្តេចសីហនុប្រកាស ។

ប៊ុន ថនៈ ចឹងហ៊ូ នឹមគាត់ពូកែខាងអក្សរសាស្ត្រ?

មាស វឿនៈ គាត់បែបជំនាញខាងហ្នឹងហើយបានគាត់កាន់ខាងហ្នឹង ប៉ុល ពតកាលនោះពីណាមាន ជំនាញខាងណាគាត់រៀបចំខាងហ្នឹងឯង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ បើហ៊ូ យន់គាត់មានកំហុស ។

ប៊ុន ថនៈ ពីរនាក់ហ្នឹងបងប្អូនគ្នាទេ?

មាស វឿនៈ មិនមែនទេ ហ៊ូ យន់ គាត់បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កណ្តាលរបស់បក្សដូចអីនៅ បូព៌ានេះ ។

ប៊ុន ថនៈ សោ ភឹម?

មាស វឿនៈ អើយ!ដូចជាសោ ភឹម គណៈប្រធានរដ្ឋនិងគណៈកម្មាធិការកណ្តាល ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់បានប្រជុំជាមួយប៉ុល ពត ហ៊ូ យន់គាត់ថាប្រទេសយើងរំដោះហើយយើងត្រូវការ កសាងប្រទេសយើងរបៀបយ៉ាងម៉េច កាលហ្នឹងប៉ុល ពតប្រជុំហើយគាត់សួរមតិយោ បល់ប៉ុណ្ណឹងទេ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ តើប្រទេសយើងមាននាយទុនទៀតទេ ឬមានលុយកាក់ចាយដែលឬយ៉ាងម៉េច? ដើម្បី កសាងប្រទេសយើងមានលោកសង្ឃមានវត្តអីទៀតទេ? ប៉ុល ពត គាត់ចង់សួរចឹង? ដល់នេះហ៊ូ យន់គាត់មានប្រសាសន៍ថា យើងអាចចាយលុយខ្លះទៅ គាត់មិនបាន និយាយដល់រឿងវត្តទេ បើគាត់មានទំនាស់គាត់មានទំនាស់ប៉ុណ្ណឹងឯង ហើយប៉ុល

ពតគាត់មិនត្រូវការវត្ត ព្រោះកសាងវត្តហ្នឹងត្រូវចំណាយមនុស្សច្រើនណាស់ មនុស្ស មិនបានកសាងប្រទេសទាំងអស់គ្នាទេ អ្នកដេកស៊ីនោះវាច្រើន ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ មែនទែនដូចថាក្នុងមួយវត្តមាន៥០នាក់ចឹង ចុះ១០០វត្តឃើញប៉ុន្មាន ដូច្នេះមនុស្សដែល ចាំស៊ីវាច្រើនគ្នា អ្នកធ្វើនោះវាមិនគ្រប់ កាលហ្នឹងហ៊ូ យន់គាត់សុំមានយោបល់តែបោះ ពុម្ពលុយតែប៉ុណ្ណឹងឯង កាលហ្នឹងលុយត្រូវបានបោះពុម្ពហើយមានលុយហើយ លុយខ្ញុំ បានឃើញដែរ តែមិនទាន់បានចាយ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹងលុយហ្នឹងយកទៅឲ្យកងពលយកទៅឲ្យក្រសួងឲ្យមន្ទីរស្អីទាំងអស់ ដើម្បីត្រូវ ពិភាក្សាគ្នាថាចាយឬមិនចាយ កាលហ្នឹងពុថាសម្រេចត្រូវចាយ ដល់ហើយមកស្រាប់តែ បាត់ហ៊ូ យន់ ខ្ញុំបានឃើញហើយតែមិនបានដឹងថាមានចាប់ពីក្រដាសប៉ុន្មានខ្លះ មានឃើញ រូបកង់ទ័ពអីហ្នឹង តែក្រោយមកបាត់គាត់ខ្ញុំមិនដឹងមានទំនាស់រឿងអីទៀតទេ ហ្នឹងមិត្តភក្តិខ្ញុំ ប្រាប់ចឹង ។

ប៊ុន ថនៈ ចឹងពីណាដែលនិយាយប្រាប់អ៊ំហ្នឹង?

មាស វឿនៈ មិត្តភក្តិខ្ញុំស្លាប់អស់ហើយ ស្លាប់បាត់ខ្លួនអស់ច្រើនណាស់ នៅសល់តែខ្ញុំម្នាក់ទេ ស៊ូ ម៉េត ថានៅបាត់ដំបង មិត្តភក្តិខ្ញុំដូចជា អាវវៃស្លាប់អស់ហើយ យូរៗឃើញមួយតែចាស់អស់ ហើយតែកាលទំនាស់របស់ហ៊ូ នឹម ហ៊ូ យន់ខ្ញុំឃើញមានតែប៉ុណ្ណឹងទេ តែមានរឿងអី ផ្សេងទៀតខ្ញុំមិនបានដឹងទេ បង១គាត់ជាអ្នកចេះដឹង មែនទែនហ៊ូ នឹមគាត់មានសញ្ញាប័ត្រ ពីរជាន់ មានស្រុកបារាំងមួយជាន់មានស្រុកខ្មែរមួយជាន់ទៀត ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹងខ្ញុំជួបអៀង សារីខ្ញុំសួរគាត់ដែរ ខ្ញុំថាអ៊ីបញ្ញាជនទាំងអស់ហ្នឹងយ៉ាងម៉េចបានឲ្យ គាត់ស្លាប់អស់ចឹង? ខ្ញុំសួរអ៊ំអៀង សារី ។

ប៊ុន ថនៈ បាទ!គាត់ឆ្លើយថាម៉េច?

មាស វឿនៈ គាត់ឆ្លើយថា ខ្ញុំក៏មិនដឹងដែរមិត្ត គាត់ថាចឹង ខ្ញុំសួរគាត់យើងរួបរួមជាតិហើយហ្នឹង ណាស់ អីថាធ្វើសម្ព័ន្ធភាពជាមួយបញ្ញាជនឥស្សរៈជនហើយយ៉ាងម៉េចបានជាបាត់អស់ចឹង គាត់ឆ្លើយប្រាប់ខ្ញុំថាចឹង ខ្ញុំជាអ្នកកសិករទេតែមានការយល់ដឹងបន្តិចបន្តួច ។

ប៊ុន ថនៈ កាលហ្នឹងអីសួរគាត់ផ្ទាល់?

មាស វឿនៈ ខ្ញុំសួរគាត់ផ្ទាល់ហ្នឹងឯង ។

ប៊ុន ថនៈ កាលហ្នឹងសួរគាត់នៅណាវិញ?

មាស វឿនៈ កាលហ្នឹងគាត់នៅម៉ាឡៃហ្នឹងឯង កាលហ្នឹងគាត់នៅកន្លែងសាគាំងរបស់សេម្ដចសីហនុ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ដូចជា តា គង់ឥវ៉ាន់ដែលនៅម៉ាឡៃហ្នឹង តា គង់ក្បាលឆកហ្នឹង អូនឯងដែលចូលដែរ ។

ប៊ុន ថនៈ គង់ ស៊ីគឿន?

មាស វឿនៈ គង់ ហៅគឿនហ្នឹងដឹង គាត់ជាសាស្ត្រាចារ្យ ហើយឡុងណារិនអីហ្នឹង ដែលជួបទេ ពេទ យុនណាល់អីមានដែលជួបទេ តែទើបយុនណាល់មិនសូវចិត្តស្និតជាមួយខ្ញុំទេ ។

ប៊ុន ថនៈ ចឹងពូមានស្គាល់តា ចៀមទេ?

មាស វឿនៈ តា ចៀមហ្នឹងជួបគ្នាព្រឹមល្ងាចហ្នឹង ឈឹម ប៊ុន្នីអីនេះ សុទ្ធតែក្រុមឆ្នាំងបាយជាមួយគ្នាតើ ។

ប៊ុន ថនៈ ចឹងនៅពេលដែលអីជួបគាត់សួរទៅគាត់ឆ្លើយតែប៉ុណ្ណឹងទេ?

មាស វឿនៈ គាត់ឆ្លើយថាមិនបានដឹងដែរ គាត់ធ្វើតែកិច្ចការផារបរទេសគាត់ថាចឹង ខ្ញុំមិនបានដឹងថាបង ប្អូនមានគ្រោះថ្នាក់ចឹងដែរ ហើយខ្ញុំនិយាយទៅកាន់គាត់ថា ចុះអឹងឯងនាំគេពីបារាំងមក នោះយ៉ាងម៉េចបានអីថាមិនដឹង ខ្ញុំដេញដោលដែលខ្ញុំមានខ្វាចអី ។

ប៊ុន ថនៈ ចឹងគាត់ថាយ៉ាងម៉េចទៀតទៅ?

មាស វឿនៈ គាត់មានថាម៉េចទេ គាត់ឆ្លើយថាចឹងឯង គាត់ថាតែមិនដឹង គាត់ថាគាត់ខ្វាចគេដែរ ។

ប៊ុន ថនៈ ចឹងអី អៀង សារីគាត់និយាយថា គាត់ខ្វាចគេដែរ?

មាស វឿនៈ ហ្នឹងហើយគាត់ថាចឹង គាត់ខ្វាចគេដែរ ។

ប៊ុន ថនៈ គាត់ខ្វាចពីណា?

មាស វឿនៈ គាត់ខ្វាចប៉ុល ពតដែរ ប្រពន្ធអៀង សារីនិងប្រពន្ធប៉ុល ពតមិនជាសាច់ញាតិគ្នា សួរខាំ ខ្ចួយមិនត្រូវជាសាច់ញាតិអ្នកស្រីបុប្ផារិននិងសួរខាំ ខ្ចួយមិនត្រូវជាសាច់ញាតិជុំវិញហ្នឹង

គ្រាន់តែខុសទស្សនៈគ្នាតែប៉ុណ្ណឹងឯង ប៉ុល ពតជាមួយគ្រួសារអៀង សារីក៏ជាពោះមួយហ្នឹងគ្នា ។

ប៉ុន ថនៈ បាទ ។

មាស វឿនៈ ចឹងត្រូវសាច់ថ្លៃគ្នាទៅវិញទៅមក ខៀវ ប៉ុណ្ណារីអីហ្នឹង យើងជាដើររកពត៌មានយើងដឹងហើយយើងមិនបាច់និយាយច្រើនទេ ។

ប៉ុន ថនៈ ចឹងកាលហ្នឹងពូមានហ៊ានសួរកាលដែលគាត់ប្រមូលនិសិត្សមកពីខាងក្រៅទេ?

មាស វឿនៈ កាលហ្នឹងខ្ញុំសួរតើ ខ្ញុំថាអឹយកនិសិត្សមកនោះ គាត់ថាបានទទួលមកដែល តែខ្ញុំមានបានគ្រប់គ្រងឯណា គាត់គិតតែការងារបរទេសឯណោះ កិច្ចការងារដូចជាទូតណាណីនោះ គាត់មិនបានគ្រប់គ្រងឯណា គាត់គ្រាន់តែថានរណាចេះអីៗគាត់ហៅមកដើម្បីជួយធ្វើការងារហ្នឹងទៅ គាត់ធ្វើការងារបរទេសផ្សេងទៅ គាត់ទទួលការងារបទេសមិនចឹងដូចជាហោ ណាំហុងចឹង ដូចចឹង ហើយគាត់មានបានមកគ្រប់គ្រងឯណា គាត់គ្រប់គ្រងតែស្ថានទូតចឹង ហ្នឹង មានបានមកគ្រប់គ្រងពួកនិសិត្សអីចឹងផង ។

ប៉ុន ថនៈ ចឹងអ៊ំនិយាយថា មានសោ ភឹមមានកន្លែងចុះយន្តហោះមានស្រីយួនមកហ្នឹង តើជាការពិតទេ?

មាស វឿនៈ ខ្ញុំបានឮតាមមិត្តភក្តិទេ ដែលនិយាយប្រាប់ហ្នឹង ខ្ញុំមិនបានទៅឃើញគាត់ទេ ។

ប៉ុន ថនៈ បាទ ។

មាស វឿនៈ មិត្តភក្តិនិយាយប្រាប់ថា នៅតាមព្រំដែនសោភឹមមានកន្លែងចុះយន្តហោះមានវៀតណាមមកនិយាយពិភាក្សាមានយកស្រីមកឲ្យសោភឹម ខ្ញុំឮតែគេថាទេ តែខ្ញុំមិនបានឃើញទេ តែក្រៅពីហ្នឹង ខ្ញុំនិយាយហ្នឹងជារឿងពិត ។

ប៉ុន ថនៈ បាទ ។

មាស វឿនៈ ដូចជា ចេង អនអីហ្នឹងមានគេចាប់មិនដឹងជារឿងស្អីផង វាមានហេតុការណ៍មួយចេះអ្នកធ្វើការនៅក្នុងក្រសួងអីហ្នឹង មានពោងមួយបណ្តែតមកតាមទន្លេបួនមុខហ្នឹង ពោងហ្នឹងជាសាររបស់ពីណាយើងមិនបានដឹងទេ តែព្រឹកឡើងគេឃើញបណ្តែតមកៗហើយគេប្រាប់ថាមានពោងអីអណ្តែតពីទន្លេហ្នឹងមក ដល់ហើយគេឃើញអក្សរសូវៀត ។

ប៉ុន ថនៈ បាទ ។

មាស វឿនៈ គេសរសេរដាក់ក្នុងពោងហ្នឹង ដល់ហើយគេដឹងថារបស់សូវៀត កាលហ្នឹងមិនដឹងថាមាន “កា សេ បេ” របស់សូវៀតកាលហ្នឹង ។

ប៊ុន ថនៈ    បាទ ។

មាស វឿនៈ ក្អាក់ឆាររបស់សូវៀតគេហៅថា "កា សេ បេ" បណ្តែតមកមានឯកសារនៅក្នុងហ្នឹង យើងកាលហ្នឹងមិនដឹងថាជាអក្សរសូវៀតអីទេ ទាល់តែហៅបុគ្គលិកចិនទៅមើល ចិនវាដឹង ថាជាអក្សរសូវៀត វាដឹងថាជាក្អាក់ឆារ"កា សេ បេ"របស់សូវៀត ។

ប៊ុន ថនៈ    ចឹងខាងណាដែលបានឃើញពោងហ្នឹង?

មាស វឿនៈ ពួកកម្មកររោងចក្រគេ កម្មកររោងចក្រតម្បាញគេឃើញ ។

ប៊ុន ថនៈ    ចឹងដល់ឃើញគេរាយការណ៍ទៅខាងណាវិញ?

មាស វឿនៈ គេរាយការណ៍មកខាងអគ្គការនេះ មកខាងប៉ុល ពត ខាងក្រសួងគេហ្នឹង អាហ្នឹងគេប្រាប់ ខ្ញុំទេ ខ្ញុំដឹងដំណឹងតៗគ្នាមក ដល់រាយការណ៍មកគេហៅចិនទៅមើល អ្នកទាំងអស់ហ្នឹងគេ មិនបានស្គាល់អក្សរនៅជាប់និងពោងហ្នឹងទេ ទាល់តែហៅចិនទៅមើលបានដឹងថាជាអក្សរ
របស់សូវៀត ។

ប៊ុន ថនៈ    បាទ!មានដឹងឯកសារនៅក្នុងហ្នឹងនិយាយពីអីខ្លះដែរ?

មាស វឿនៈ  ខ្ញុំមិនបានដឹងទេ ត្រង់ហ្នឹងគេប្រាប់ខ្ញុំតែប៉ុណ្ណឹងទេ ព្រោះខ្ញុំនៅនេះ ។

ប៊ុន ថនៈ    បាទ!ចឹងមានមូលហេតុហ្នឹងបានជាគេចាប់ចេង អន?

មាស វឿនៈ បាទ!មូលហេតុហ្នឹងដែលគេចាប់ចេង អន ។

ប៊ុន ថនៈ    ចឹងមានឯកសារហ្នឹងនិយាយទាក់ទងជាមួយចេង អន?

មាស វឿនៈ ប្រហែលហើយដឹងបានជាទៅបាត់អស់ចឹង ។

ប៊ុន ថនៈ    ចឹងអ៊ំមានបានដឹងថា ចេង អនគាត់កាន់ក្រសួងអីច្បាស់លាស់?

មាស វឿនៈ ចេង អន កាលហ្នឹងគាត់កាន់ក្រសួងពាណិជ្ជកម្មរដ្ឋយូរហើយ តាំងពីឈ្នះឆ្នាំ៧៥គាត់ទទួល រហូតមក គាត់បានឡើងមន្ត្រីហ្នឹងរហូត ។

ប៊ុន ថនៈ    ចឹងដូ ចេតហៅស៊ីហ្នឹង គាត់ទាក់ទងរឿងរដ្ឋប្រហាហ្នឹង តើគាត់មានរឿងហេតុអីផ្សេង ទៀតអ៊ំ?

មាស វឿនៈ ដូ ចេតហ្នឹងទាក់ទងរដ្ឋប្រហានិងបក្សដឹកនាំ ដូចថាមានបំណងរំលំលេខាបក្សចឹង ។

ប៊ុន ថនៈ    បាទ ។

មាស វឿនៈ ពាក្យលេខាបក្សយើងយល់មែនទេ ។

ប៊ុន ថនៈ    បាទ ។

មាស វឿនៈ លេខាបក្សហ្នឹងគឺជាអ្នកកំពូល ជាអ្នកដឹកនាំរដ្ឋដូចថាជាអ្នកកាន់ចង្កូតណាស់ ។

ប៊ុន ថនៈ បាទ! ចឹងក្រោយពីចាប់ដូ ចេតហើយមានពីណាឡើងជំនួសគាត់?

មាស វឿនៈ ទេ ដូចជាមិនព្វ កាលហ្នឹងដូចជាមិនទាន់មានផ្សាយឈ្មោះទេ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងមិនមានប្រធានទេ នៅចំហរចោល?

មាស វឿនៈ ចំហរចោលមិនដឹង គេចាត់តាំងសម្ងាត់ខ្ញុំមិនបានដឹង បើគេមិនបានផ្សាយយើងក៏មិនបាន ដឹងដែរ ។

ប៊ុន ថនៈ ចឹងកាលអ៊ំទទួលការចាត់តាំងពី តា ម៉ុកដែលនោះនៅពេលណា?

មាស វឿនៈ រឿងបញ្ជាពីតា ម៉ុក ខ្ញុំនៅជាទាហាននោះ ទាហានមិនមានបញ្ជាពីតា ម៉ុក ។

ប៊ុន ថនៈ ហ្នឹងក្រោយហើយអ៊ំ?

មាស វឿនៈ ក្រោយយ៉ាងម៉េចតាំងពីតស៊ូមកមានតា ម៉ុកហ្នឹងឯង ដល់ក្រោយមកគេរៀបចំជើងគោក ជើងអាកាស ជើងទឹក កាលហ្នឹងអគ្គសេនាធិការមានសុន សេនមិនចឹង គណៈបញ្ជាការ សមរភូមិមិនតា ម៉ុកមិនចឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហ្នឹងតា ម៉ុកជាអ្នកចុះផ្ទាល់ហើយសុន សេនគ្រាន់តែបញ្ជាតើ តា ម៉ុកគាត់ជាអ្នកចុះ ផ្ទាល់អាហ្នឹងមិនអគ្គមេបញ្ជាការដ្ឋាន ចុះផ្ទាល់ក្នុងសមរភូមិមិនតា ម៉ុក ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ តា ម៉ុក គាត់បញ្ជាទ័ពណាក៏បានដែរ គេមិនខ្វល់ដូចកែវ គឺមយ៉ានចឹង យើងលើកឧទាហ ណ៍ចឹង ។

ប៊ុន ថនៈ បាទ!ចឹងអ៊ំមានការផ្លាស់ប្ដូរចាប់ច្រើនចឹង មានការណែនាំមកពីខាងមជ្ឈិមអីមកដែរ?

មាស វឿនៈ នៅខាងព្រំដែនគាត់ណែនាំពីសត្រូវខាងក្រៅទេ យើងត្រូវការពារទឹកដីយើងត្រូវអត់ធ្មត់ បើគេតបតយើង យើងកុំតបតគេយើងត្រូវមានការអត់ធ្មត់ កុំឲ្យមានការប៉ះពាល់រឿង អ៊ីៗ ដូចថាគេឃើញយើងគេបាញ់បន្តិចបន្តួចអីយើងកុំតបតគេយើងស្ងាត់ស្ងៀមទៅ កុំឲ្យ កើតមានដូចថា គេបាញ់ហើយយើងបាញ់ទៅវិញបានន័យថាយើងបង្កកើតឡើងជារឿង ធំណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ អាហ្នឹងគេប្រាប់យើងតែប៉ុណ្ណឹងទេ យើងការពារតែទឹកដីជើងទឹក ជើងគោកជើងអាកាស កុំឲ្យខ្មាំងវារំលោភវាឈ្លានពាន កុំខ្មាំងវាយកតែប៉ុណ្ណឹងទេ

រឿងខាងព្រំដែននោះវាមិនមាន   រឿងអីទេ   អត់មានណែនាំអីក្រៅពីទឹកដីការពារហ្នឹងទេ បើមានពីណារត់កាត់ព្រៃឆ្លងទៅអី  ឃើញត្រូវវាយការណ៍ ។

ប៊ុន ថនៈ  បាទ ។

មាស រឿនៈ  កាលពីដើមគេហៅថាចោរព្រៃឬចោររត់យើងមិនដឹងដែរ   បើឃើញយើងចាប់បញ្ជូនទៅ ថាមនុស្សហ្នឹងទៅណាឬរត់ឆ្លងទៅណាទៅណី ។

ប៊ុន ថនៈ  ចឹងមានផែនការណែនាំពីចោរព្រៃអីដែរ?

មាស រឿនៈ  បាទ ។

ប៊ុន ថនៈ  កាលហ្នឹងមានចោរព្រៃច្រើនទេ?

មាស រឿនៈ  ចោរព្រៃមិនមានទេ ខាងកោះកុងនេះមានតែយួនវារត់តាមទូកតាមកាណូត  ហើយមក តាមច្រកយើងមាន មានរាប់រយនាក់វារត់ទៅថៃដើម្បីទៅអាមេរិច ។

ប៊ុន ថនៈ  បាទ ។

មាស រឿនៈ  កាលហ្នឹងយួនខាងជើងវាវៃយួនខាងត្បូងពីដើម   អូនឯងអាចដឹងហើយយួនខាងត្បូងវា សេរីយួនខាងជើងវាកុំម្មុយនីស្ត  យួនខាងត្បូងយួនធៀវគឺមិនសេរី  ហើយធៀវគឺហ្នឹងត្រូវគ្នាជាមួយអាមេរិកត្រូវគ្នាជាមួយលន់ នល់ ។

ប៊ុន ថនៈ  បាទ ។

មាស រឿនៈ  ដល់ចឹងទៅវាចាញ់យួនខាងជើងទៅវាត្រូវរត់  ចឹងវាត្រូវរត់កាត់ឆ្លងសមុទ្រយើង  វាចង់ឆ្លងកាត់ទៅថៃចឹងយើងចាប់ដែរ   អាណាវាទៅៗអាណានៅៗទៅយើងចាប់បញ្ជូនគេមក ខាងកំពង់សោមមកគេចរចារគ្នាលែងមកខាងណាខាងណីខ្ញុំមិនដឹងដែរ ។

ប៊ុន ថនៈ  ចឹងមានបញ្ជូនមកខាងណាដែរ?

មាស រឿនៈ  សេនាធិការ ។

ប៊ុន ថនៈ  សេនាធិការនៅណា?

មាស រឿនៈ  សេនាធិការប្រចាំនៅកំពង់សោម   គេដោះស្រាយយ៉ាងណាយើងមិនដឹង   យើងគ្រាន់តែចាប់ហើយបញ្ជូនមក  គេចចារលែងស្រេចតែគេទេ  ការសារបរទេសគេចចារគ្នាយ៉ាងម៉េច យើងមិនបានដឹងដែរ ។

ប៊ុន ថនៈ  ចឹងកាលហ្នឹងចក្រីអីហ្នឹងគាត់នៅខាងជំនួយការសេនាធិការដែរ?

មាស រឿនៈ  រឿងចក្រីយើងមិនបានទទួលផែនការពីហ្នឹង  ខ្ញុំដឹងពីសុន  សេន  ខ្ញុំអត់មានបានទទួលពីចក្រីទេ  ព្រោះចក្រីមិនបានមកបញ្ជានៅខាងនេះឯណា ។

ប៊ុន ថន: បាទ ។

មាស វឿន: បើជើងទឹកឬជើងគោកមកត្រួតដល់តាមព្រំឬតាមសមរភូមិ ។

ប៊ុន ថន: ចឹងអ៊ីដឹងថាគាត់នៅខាងអគ្គសេនាធិការដែរ?

មាស វឿន: ទេ ខ្ញុំមិនបានដឹងទេ ខ្ញុំដឹងថាសេនាធិការខាងឈូក អរ!អា វ៉ែននៅខាងជើងគោក ចាំមើលណាឈូកហ្នឹងខាងជើងគោកក៏មិនដឹងទេ តែពីដើមនៅខាងជើងគោកជាមួយវ៉ែនហ្នឹងកូនប្រសារតា ម៉ុកណាស់ ។

ប៊ុន ថន: បាទ ។

មាស វឿន: ខ្ញុំនឹកឃើញហើយ ឈូកនៅជាមួយវ៉ែនកូនប្រសារតា ម៉ុក តែមិនដឹងថាឈូកជាប្រធានវ៉ែនជាអនុ ដល់ខាងជើងអាកាសស៊ូ សាម៉េតនិង វវៃពីរនាក់ហ្នឹង ហើយខាងជើងទឹក តាមុតកូនប្រសារតា ម៉ុក ដែរ ។

ប៊ុន ថន: បាទ ។

មាស វឿន: តា មុតនិងជីដូនមួយខ្ញុំឈ្មោះ សា វឿន គាត់នៅខាងជើងទឹកដែរ ខ្ញុំដឹងតែប៉ុណ្ណឹងឯងតែបើពីណាមកត្រួតខ្ញុំ ខ្ញុំមិនដឹងទេ ខ្ញុំដឹងថាសេនាធិការឬភូមិភាគចុះមកផ្ទាល់ខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹងឯង តែពួកហ្នឹងតាំងពីរៀបចំខ្ញុំហើយមិនដែលមកដល់ខ្ញុំទេ ។

ប៊ុន ថន: បាទ!ចុះមកតែតា ខៀវ?

មាស វឿន: តា ខៀវ ក៏មិនដែលចុះមកដែរ ទាក់ទងគ្នាតាមតែទូរលេខនិងតាមវិទ្យុអាធំ ខ្ញុំជួនកាលបញ្ជាពីគាត់ទៅ ជួនកាលបញ្ជាពីកងពលទៅ ប្រធានកងពលខ្ញុំបងសឿងទៅ គាត់នៅប្រចាំភូមិភាគដែរ ក្នុងមួយខែឬមួយអាទិត្យអីគាត់មកខ្ញុំចឹងមកទៅៗ ហើយខ្ញុំបាននៅជាប់រហូត ។

ប៊ុន ថន: ចឹងកាលចាប់កងពលមួយៗអីអ៊ីមានបានដឹងខ្វះទេ?

មាស វឿន: ខ្ញុំមិនបានដឹងទេ

ចំពោះកងពលដូចជាមិនបានចាប់ពីណាចំពោះកងពលដ៏ទៃខ្ញុំមិនបានដឹងដែរ

ព្រោះនៅឆ្ងាយពីគ្នា គេមិនសូវឲ្យដឹងដែរ ។

ប៊ុន ថន: ចឹងកាលចាប់ពីនអីអ៊ីមានបានដឹងទេ?

មាស វឿន: តា ពីនហ្នឹងជាជីដូនមួយហ្នឹងគ្រួសារខ្ញុំ តា ពីនខ្ញុំដឹងខ្ញុំស្គាល់ជួបជិបូងបង្អស់ជួបគាត់នៅកំពង់ឆ្នាំង តែកាលស្គាល់គាត់ហ្នឹងមិនដឹងថាគាត់នៅកងពលលេខប៉ុន្មានទេ តែកាលគេចាប់ គាត់នោះខ្ញុំមិនបានដឹងទេ គាត់នៅខាងបូព៌ាឯណោះ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់មានបានមកនៅខាងខ្ញុំឯណា យើងដឹងដំណឹងថាចាប់គា ពីន គ្រាន់តែបានដឹង តែគេចាប់រឿងអីៗខ្ញុំមិនបានដឹងទេ ហើយមួយទៀតបងជីដូនមួយខ្ញុំឈ្មោះ បងអៀវ គាត់ស្រីទេ គាត់ជាកម្មាភិបាលដែរ គាត់ទៅនៅខាងបូព៌ាហ្នឹងជាមួយ នង សួន គេចាប់ដែរ តែខ្ញុំមិនបានដឹងថាគេចាប់រឿងអី ខ្ញុំដឹងតាមក្មួយខ្ញុំនៅម៉ាខ្សែនេះ ។

ប៊ុន ថនៈ ចឹងណាគអឹមានស្គាល់ទេ?

មាស វឿនៈ ណាគខ្ញុំឮតែឈ្មោះ ខ្ញុំមិនដែលស្គាល់ទេ ។

ប៊ុន ថនៈ ចឹងតា ឌុចអីអឹមានស្គាល់ទេ?

មាស វឿនៈ ឌុចខ្ញុំទើបស្គាល់គាត់នៅទីនេះទេ គាត់នៅស្រុកថ្មពួកនេះឯង គាត់មកធ្វើពាណិជ្ជកម្មជាមួយ ប្រជាជននៅស្រុកថ្មពួកនេះ ខ្ញុំទើបស្គាល់គាត់នៅហ្នឹងឯង ស្គាល់គាត់កាលឆ្នាំអ៊ុន គាត់ ចូលមកហើយហ្នឹង ។

ប៊ុន ថនៈ បាទ!ចឹងកាលសម័យតស៊ូអឹអត់មានស្គាល់ទេ?

មាស វឿនៈ អត់ទេ ខ្ញុំស្គាល់តែប្រពន្ធគាត់ដែលគេសម្លាប់ហ្នឹងណាស់ គេបាញ់សម្លាប់នៅផ្ដាំនេះ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ខ្ញុំដឹងថាប្រពន្ធគាត់ចេញជាមួយខ្ញុំនៅជាមួយខ្ញុំប្រពន្ធគាត់ឈ្មោះ រុំ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ រុំហ្នឹងគាត់ខ្មៅ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់នៅជាមួយខ្ញុំ ដល់គាត់យកតា ឌុចទៅខ្ញុំមិនបានដឹងគាត់ទៀត គាត់នៅជាមួយខ្ញុំយូរហើយតាំងពីឆ្នាំ៦៧-៦៧ម្ល៉េះ ។

ប៊ុន ថនៈ បាទ!ចឹងគាត់ជាកម្មាភិបាលដែរ?

មាស វឿនៈ បាទ!គាត់ចេញតាំងពីឆ្នាំ៦៧-៦៨មក កាលហ្នឹងគាត់ជាកុមារជានារីណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹងគេមានសម្ព័ន្ធភាពនារីទីក្រុងនិងនារីជនបទ តែដល់គាត់បានប្ដីទៅបែកគ្នារហូតទាល់តែគាត់ជាប់គុកហ្នឹងឯង គាត់ជឿព្រះគ្រីះខ្ញុំក៏ជឿព្រះគ្រីះដែរ ទើបគ្រូខ្ញុំប្រាប់ថាឌុចហ្នឹង គ្រូខ្ញុំបានទៅថ្វាយបង្គំបានជួបគាត់រាល់ខែដែរ ។

ប៊ុន ថនៈ ចឹងកាលពូថាបានទទួលការណែនាំពីប៉ុល

ពតទៅព្រះវិហារដល់វៀតណាមចូលមកឬមួយទៅ ណាទៀតដែលពូ?

មាស វឿនៈ ខ្ញុំទទួលការណែនាំពីប៉ុល ពតមកខ្ញុំនៅរហូតដល់យួនវ៉ៃ ចូលវ៉ៃបានភ្នំពេញទាំងអស់ហើយ ខ្ញុំមកតាមហ្នឹងមក ខ្ញុំនៅបានបួនខែ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ខ្ញុំនៅបានបួនខែពេញ ។

ប៊ុន ថនៈ មកនៅណាវិញពូ?

មាស វឿនៈ ខ្ញុំចេះតែរត់ដើរតាមហ្នឹងមក តាមភ្នំដងរែកហ្នឹងមកព្រះវិហារមក មកដល់ឧត្តរមានជ័យ ហ្នឹងមក មកសម្រាកនៅបន្ទាយឆ្មា ចេញមកទៅម៉ាឡៃទៅកំរៀងត្រឡប់មកវិញ ។

ប៊ុន ថនៈ កាលហ្នឹងមកច្រើនគ្នាទេ?

មាស វឿនៈ មកច្រើនកងទ័ពខ្ញុំកាលនោះទាហានយួនវ៉ៃចូលភ្នំពេញហើយ កងទ័ពខ្ញុំដែលខ្ញុំបញ្ជូនមកពី ឆ្នាំ៧៦ នៅកោះកុងដែលបញ្ជូនទៅហ្នឹងវាមកតាមហ្នឹងដែរ វាបាក់មកតាមខ្ញុំអាខ្លះនៅក្នុង ស្រុកយួន អាខ្លះវាមកតាមហ្នឹង ខ្ញុំមកជាមួយកងទ័ពខ្ញុំ កាលហ្នឹងមកជាង៧៧០០នាក់ កាលហ្នឹង ។

ប៊ុន ថនៈ ចឹងមកជុំជាមួយពូវិញ?

មាស វឿនៈ បាទ!មកជុំគ្នាវិញ កាលហ្នឹងអាខ្លះនៅម៉ាឡៃខ្លះនៅប៉ៃលិនរហូតទាល់តែឥឡូវ ។

ប៊ុន ថនៈ ចឹងអ្នកខ្លះជាប់នៅខាងយួនហ្នឹងយ៉ាងម៉េចដែរពូ?

មាស វឿនៈ នៅជាប់ខាងយួនហ្នឹង យួនមកមកស្រុកខ្មែរហើយយើងនៅក្នុងដីយួនឯណោះ ។

ប៊ុន ថនៈ ចឹងអ្នកដែលនៅហ្នឹងយ៉ាងម៉េចដែរ?

មាស វឿនៈ

ដល់ចឹងយើងទម្លាក់កាំភ្លើងចោលអស់ទៅយើងធ្វើជាប្រជាជនដើរចេញមកវិញមកមួយ ពីរ ចឹងមកៗ ។

ប៊ុន ថនៈ អឹមានដឹងថា កាលហ្នឹងជាប់ច្រើនទេ?

មាស វឿនៈ ជាប់ច្រើន ។

ប៊ុន ថនៈ ប្រហែលជាប៉ុន្មាន?

មាស វឿនៈ ជាប់ប្រហែលជាង៣០០នាក់ ហើយកងគេដទៃទៀតមិនដឹងជាប់ប៉ុន្មាន ខ្ញុំមិនបានដឹង ដែរ ។

ប៊ុន ថន: កាលហ្នឹងជាប់នៅខាងអីវិញ?

មាស វឿន: កាលហ្នឹងជាប់នៅខាងខេត្តតែនិញ ដល់អូរដាំតែអុងនោះណាស់ គាយួនដាំតែអុងខ្មែរពីដើមនោះណាស់ ។

ប៊ុន ថន: ចឹងចូលជាប់នៅខាងហ្នឹង?

មាស វឿន: ជាប់នៅហ្នឹងហើយ កាលហ្នឹងមួយឆ្នាំនោះបានចេញអស់ កាលហ្នឹងមកជាមួយខ្មែរកម្ពុជាក្រោយមក ។

ប៊ុន ថន: ចឹងអ្នកដែលជាប់នៅក្នុងហ្នឹងវៀតណាមមានចាប់បានទេ?

មាស វឿន: វាមានចាប់អី បើយើងដោះខោអាវអស់ហើយ ។

ប៊ុន ថន: ចឹងយ៉ាងម៉េចបានជាប់អត់ដឹងប៉ុន្មួយយ៉ាងម៉េច?

មាស វឿន: អត់បានដឹងនោះ បើយើងវ៉ៃនេះចូលទៅជ្រៅ ដល់នេះចូលមកពីខាងក្រចេះវិញនេះ ទន្លេបិទនេះវិញ ដូចនេះចូលមកដល់កំពង់ចាមភ្នំពេញហើយ អីនោះនៅក្នុងស្រុកយួននោះហ្នឹង ដូចនេះចូលដល់ស្ទឹងត្រែងព្រះវិហារចូលដល់ចឹងហើយអានេះចូលភ្នំពេញហើយអានោះ នៅក្នុងស្រុកយួន ។

ប៊ុន ថន: បាទ ។

មាស វឿន: មានអី មិនហ៊ានមកវិញនៅក្នុងព្រៃនាមអីទៅ រហូតអត់បាយអីទៅបានបងប្អូនកម្ពុជាក្រោយខ្មែរយើងឲ្យបាយទឹកស៊ីទៅ ឲ្យអង្ករហូបទៅចឹងហើយបោះចោលកាំភ្លើងអស់ទៅ កាលហ្នឹងមានអ្នករត់ពន្ធបារីពីថៃទៅយួនណាស់ យើងប្រឡំខ្លួនចេញមកវិញទៅយើងមក តាមហ្នឹងម្តងមួយម្តងពីរមក ។

ប៊ុន ថន: បាទ ។

មាស វឿន: មករហូតមក ។

ប៊ុន ថន: ចឹងចេញមកទាំងអស់មានរស់នៅហ្នឹងខ្លះ?

មាស វឿន: អត់មានទេ ចេញមកអស់ហើយ កាលហ្នឹងមួយឆ្នាំជាងបានមកអស់ ។

ប៊ុន ថន: ចឹងមករស់នៅជាមួយអឹងដែល?

មាស វឿន: ខ្លះរត់មកធ្វើជាទាហានវ៉ៃជាមួយយួនទៀតអាខ្លះនៅរកស៊ីធម្មតាទៅ ។

ប៊ុន ថន: ចឹងសមមត្តិសៀងរត់ចេញពីព្រះវិហារមកនេះជាមួយអីវិញហ្នឹង?

មាស វឿន: អាហ្នឹងនៅក្នុងស្រុកយើងទេ ។

ប៊ុន ថន: បាទ ។

មាស វឿនៈ កាលហ្នឹងគាត់នៅសៀមរាប គាត់ចេញពីសៀមរាបមកគេបាញ់គាត់នៅគូរនេះ គូគោក មននេះ អូនឯងស្គាល់ទេ ។

ប៊ុន ថនៈ គោកមនខត្តរមានជ័យ?

មាស វឿនៈ ហ្នឹងហើយ គេបាញ់គាត់នៅហ្នឹង ខ្ញុំនៅព្រះវិហារ កាលគេបាញ់គាត់ស្លាប់ទៅខ្ញុំនៅព្រះវិហារ ខ្ញុំមកក្រោយខ្ញុំដើរជាមួយក្រុមគ្រួសារគាត់ផង ជាមួយក្រសួងមន្ទីរគាត់ផង ។

ប៊ុន ថនៈ ចឹងមានដឹងថាខាងណាជាអ្នកបាញ់?

មាស វឿនៈ ទេ តាមមើលមិនហួសពីកូនក្មួយគាត់ទេ មិនដឹងពីព្រោះកងពលនៅខត្តរហ្នឹងមានឈ្មោះស៊ីមួយទេ ដែលប្រណែនគាត់ ប្រហែលជាកូនក្មួយគាត់មិនឆ្ងាយប៉ុន្មានទេតាមមើល មានទំនាស់គ្នាពីរឿងមុខដំណែងមុនមាត់ ។

ប៊ុន ថនៈ ចឹងអ៊ំកាលនៅម៉ាឡៃបានយូទេ?

មាស វឿនៈ នៅម៉ាឡៃបានប្រហែលជា៥ ទៅ៦ ខែប៉ុណ្ណឹងឯង ។

ប៊ុន ថនៈ ចឹងទៅដល់ហ្នឹងគេបែងចែកយ៉ាងម៉េចវិញ កំលាំងអ៊ំប៉ុន្មានពាន់នាក់ហ្នឹង?

មាស វឿនៈ កំលាំងហ្នឹងចូលសមរភូមិជាមួយសុខភាព ស្គាល់សុខភាពដែរ ។

ប៊ុន ថនៈ ស្គាល់ ។

មាស វឿនៈ ហើយកំលាំងមួយទៀតនៅប៉ៃលិន ខ្ញុំមានរបួសច្រើនពេកខ្ញុំឈប់ ខ្ញុំសុំឈប់ទៅអ៊ំអៀងសារីឲ្យខ្ញុំឈរនៅជំរំតាផ៉ុក គេហៅជំរំទី៨ គេឲ្យទៅគ្រប់គ្រងប្រជាជននៅជំរំដល់ហើយខ្ញុំ ផ្ញើមាតុភូមិមកតាមយូអ៊ិន ។

ប៊ុន ថនៈ តែកាលពីដំបូងហ្នឹងអ៊ំនៅជាកងទ័ពដែលទេ?

មាស វឿនៈ បាទ! នៅកងទ័ពរហូត ។

ប៊ុន ថនៈ កងពលលេខប៉ុន្មាន?

មាស វឿនៈ កងពល៤៥០ហើយ៥១៩ ឌុល សាវឿន ។

ប៊ុន ថនៈ ចឹងនៅជាមួយសុខ ភាព៤៥០?

មាស វឿនៈ ហ្នឹងហើយ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងអ៊ំជាប្រធានដែរ?

មាស វឿនៈ កាលហ្នឹងខ្ញុំគ្រាន់តែជំនួយការទេ ព្រោះខ្ញុំធ្វើការមិនកើត ហើយខ្ញុំបានមកនៅជាមួយឌុលសាវឿននេះ

គាត់មកឈរជើងនៅសមរភូមិខាងជើងស៊ីសាផុនយើងពីបន្ទាយមានជ័យទៅ ភ្នំស្រុកទៅ

ទៅខាងព្រះនេតព្រះចឹងទៅអាហ្នឹងនៅសមរភូមិខាងជើង ខ្ញុំនៅជាមួយឌុល សារឿន ខ្ញុំនៅជាមួយសុខ ភាពបានមួយរយៈទេ ។

**ប៊ុន ថនៈ** យ៉ាងម៉េចបានមកនៅជាមួយឌុល សារឿនវិញ?

**មាស រឿនៈ** នៅខាងនេះអត់មានអ្នកគ្រប់គ្រងចាស់ទុំ ។

**ប៊ុន ថនៈ** ចឹងឌូល សារឿនគាត់ជាមេបញ្ជាការ?

**មាស រឿនៈ** ឌុល សារឿនគាត់ជាបញ្ជាការ ។

**ប៊ុន ថនៈ** ចឹងអ៊ីជាជំនួយរបស់គាត់?

**មាស រឿនៈ** កាលនោះគាត់បញ្ជាកងពល៥១៩ហ្នឹង កាលមុនហ្នឹងមានឈ្មោះយទមួយមានខ្ញុំមានឌុល សារឿន ដល់ខ្ញុំធ្វើការមិនកើតទៅខ្ញុំឈប់ទៅ ខ្ញុំទៅគ្រប់គ្រងប្រជាជនតាមជំរំផ្អាកព្រៃមាន់ អីហ្នឹងឲ្យឌុល សារឿនគាត់ទៅមុខទៅ យន កាលហ្នឹងគាត់នៅវង់នៅបញ្ជាការគាត់នៅជា ប្រធាន ។

**ប៊ុន ថនៈ** បាទ ។

**មាស រឿនៈ** ខ្ញុំនៅខាងប្រជាជនវិញ ។

**ប៊ុន ថនៈ** ចឹងពូត្រូវរបួសឆ្នាំណា?

**មាស រឿនៈ** ឆ្នាំ៧០របួស ឆ្នាំ៧៥របួស ឆ្នាំរបួសយួននេះមិនដឹងជាឆ្នាំប៉ុន្មានទេ ប្រហែលជាឆ្នាំ៨១-៨២ហើយតាមមើល របួសខ្ញុំវាច្រើនពេកខ្ញុំវះពោះផង សព្វថ្ងៃខ្ញុំពិការជរាដែលតែគ្រាន់ខ្ញុំវាមិនបាក់ដៃបាក់ជើងប៉ុណ្ណឹង តែខាងក្នុងខ្ញុំវះខ្ទិចខ្ទីអស់គ្រាន់តែមើលមិនឃើញ ។

**ប៊ុន ថនៈ** ចឹងខាងឌុល សារឿនហ្នឹងមានប៉ារាអីទេ?

**មាស រឿនៈ** អត់មានទេ ក្រុមប៉ារាគាត់ផ្សេងទេ ។

**ប៊ុន ថនៈ** ចឹងមានប៉ះគ្នាវៃគ្នាទេ?

**មាស រឿនៈ** ខ្ញុំមិនដែលវៃគ្នាទេ ខ្ញុំមិនដែលវៃគ្នាជាមួយប៉ារាទេ ។

**ប៊ុន ថនៈ** ចឹងប៉ារានៅតំបន់ណាខ្លះ?

**មាស រឿនៈ** ប៉ារានៅតំបន់នេះទាំងអស់នេះដែរហ្នឹង ។

**ប៊ុន ថនៈ** ចឹងអ៊ឹមិនដែលចូលមកដល់ហ្នឹងទេ?

**មាស រឿនៈ** ខ្ញុំនៅខាងអាងត្រពាំងថ្មនោះ ភ្នំស្រុកនោះ ខាងនេះសុទ្ធតំបន់ប៉ារាខ្ញុំនៅខាងនោះនៅខាងព្រែកតាចាស់អីនោះ នៅខាងទន្លេនោះ ឆ្លងទៅខាងហ្នឹងវិញ នៅខាងនេះសុទ្ធតែប៉ារាទាំងអស់ហ្នឹង ដល់ប៉ារាអត់មានកន្លែងនៅទៅ មុនដំបូងខ្ញុំនៅព្រៃមាន់នេះ ព្រៃមាន់ភ្នំឆត្រនេះ

ដល់ប៉ាវាអត់មានកន្លែងនៅឲ្យប៉ាវាកាលនោះភាគីគេ តា សឺន សានគាត់អត់មានកន្លែងនៅ គេរើកន្លែងគាត់អស់ទៅ គាត់សុំកន្លែងហ្នឹងក៏ខាងភាគីគេឲ្យហ្នឹងទៅ កន្លែងខ្ញុំតើកន្លែងអស់ហ្នឹងនោះ ដល់ខាងភាគីខាងខៀវ សំដនគេឲ្យទៅខ្ញុំចុះទៅក្រោមទៅ ដល់ក្រោយមកយើងមិនរួបរួមគ្នា ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ កាលហ្នឹងយើងមិនទាន់រួបរួមគ្នាទាំងអស់ណា ប៉ាវានិងខ្មែរក្រហមរួបរួមគ្នាបានហើយខាងក្នុងខ្មែរក្រហមមិនទាន់រួបរួមគ្នាបានទេ តែដល់ក្រោយមកប៉ាវាគេរួបរួមគ្នាជាមួយរដ្ឋកម្ពុជាបាន ចឹងយើងនៅខាងឌុល សារឿន នៅខាងជុបគគីរ ខាងអន្លង់វែងខាងអីគេនៅដល់ចឹងខាងកងពលប៉ាវាហើយខាងកម្ពុជាហ្នឹងគេរួបគ្នាវ៉ៃ ពួកខាងខ្មែរក្រហមទៀត ខាងភ្នំឆត្រអីនេះកន្លែងពួក តា ខៀវ សំដនគាត់នៅភ្នំឆត្រតើកាលមួយហ៊ុកហ្នឹង ប៉ុល ពតក៏នៅភ្នំឆត្រ តា ឌុចគាត់នៅភ្នំឆត្រហ្នឹងដែរ ដល់ពេលវ៉ៃចឹងទៅគេសប្បាយនិងជ័យភ័ណ្ឌថៃ យកដីអស់ប៉ុន្មានដាងមួយគីឡូមានអីអស់ដីរលីង ។

ប៊ុន ថនៈ ខាងណាវ៉ៃ?

មាស វឿនៈ ចុះកាលហ្នឹងខាងកងពលប៉ាវានិងកងពលខាងក្នុងមិនវ៉ៃខ្មែរក្រហមចុងក្រោយបំផុតមិនវ៉ៃយកជ័យភ័ណ្ឌអស់យកភ្នំឆត្រអីហ្នឹង ដល់យកជ័យភ័ណ្ឌហើយថៃមិនរុកមកយកដីហ្នឹងអស់ រលីង ។

ប៊ុន ថនៈ ចឹងកាលហ្នឹងពួរត់ទៅណាទៅ?

មាស វឿនៈ ខ្ញុំនៅថ្មពួកនេះឯង ខ្ញុំមកតាម“យូអ៊ិន”ខ្ញុំឈប់ធ្វើទាហានហើយ ។

ប៊ុន ថនៈ ចឹងតា ឌុចមកនៅជាមួយខៀង សំដនហ្នឹង?

មាស វឿនៈ បាទ! គាត់មកនៅហ្នឹងគាត់ធ្វើពាណិជ្ជកម្មហើយគេសម្លាប់ប្រពន្ធគាត់នៅហ្នឹងឯង ។

ប៊ុន ថនៈ ចឹងគាត់កាន់ខាងពាណិជ្ជកម្ម?

មាស វឿនៈ ហ្នឹងហើយគាត់កាន់ខាងពាណិជ្ជកម្ម ដោះដូរចេញដូច ដល់គេវ៉ៃទៅប៉ុល ពតប្រាប់គាត់ដែលថា តា ឌុចឯងទៅនៅខាងក្នុងមានពីណាការពារឲ្យហ្នឹង ចឹងតា ឌុចសុខចិត្តនៅក្នុងកាលហ្នឹងគេវ៉ៃទៅ អីៗអស់ហ្នឹងគាត់ទៅនៅអន្លង់វែងអស់ទៅ ។

ប៊ុន ថនៈ ចឹងកាលហ្នឹងប៉ុល ពតសួរគាត់ដែរ?

មាស វឿន៖ ហ្នឹងហើយគាត់សួរគា ឌុចដែលតើ ថា ឌុចឯងនៅខាងក្នុងឬនៅក្រៅ គា ឌុចថានៅក្នុង នៅទៅ ថានៅអត់មានពីណាការពារទេណា ដល់នៅគាត់សុខចិត្តនៅទៅ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ គាត់នៅបានយូរដែលហ្នឹង រហូតដល់គេរដ្ឋប្រហាទៅ វ៉ៃសម្លាប់ប្រពន្ធគាត់ ។

ប៊ុន ថន៖ ចឹងគាត់មានដែលឡើងប្រជុំនៅភ្នំឆត្រែទេ?

មាស វឿន៖ បាទ! ផ្ទះគាត់នៅហ្នឹងតើ គាត់គ្រាន់តែធ្វើពាណិជ្ជកម្មទៅមកៗ តែប្រពន្ធគាត់នៅខាងក្នុង ដល់នេះទៅគាត់ដាក់ឈ្មោះធ្វើជាគ្រូបង្រៀនវិទ្យាល័យនៅផ្គាំហ្នឹងឯង ។

ប៊ុន ថន៖ ចឹងប្រជាជនមានដឹងថាគាត់ធ្វើជាពាណិជ្ជកម្មដែរ?

មាស វឿន៖ ដឹងតើៗ គេដឹងទាំងអស់គ្នា ។

ប៊ុន ថន៖ ចឹងអ្នកនៅផ្គាំមានដឹងទេ?

មាស វឿន៖ អ្នកស្រុកនៅផ្គាំគេដឹង អូនឯងទៅសួរខឿន សុខាគេដឹងហើយ ខឿន សុខាហ្នឹងគាត់ជឿព្រះគ្រឹះនៅជិតផ្ទះគាត់ហ្នឹងឯង ។

ប៊ុន ថន៖ ចឹងតាមពិតគាត់នៅតែមានទាក់ទងជាមួយខ្មែរក្រហមដែរ?

មាស វឿន៖ បាទ!អ្នកស្រុកក៏គេដឹងដែរ គេដឹងថាគាត់ជាពាណិជ្ជកម្មខ្មែរក្រហមគេមិនដឹងលុយគេច្រើន ដល់នេះគេសម្លាប់ ។

ប៊ុន ថន៖ ចឹងកាលសម្លាប់ហ្នឹងដោយសាររឿងប្លន់ឬមួយជារឿងនយោបាយ?

មាស វឿន៖ បើតាមមើលទៅគេសម្លប់គាត់ មានន័យថាគេស្អប់ខ្មែរក្រហមយើងនិយាយឲ្យខ្លីចឹងទៅ គេស្អប់ខ្មែរក្រហមណាមួយគា ឌុចហ្នឹងគាត់ជាអ្នកចេះដឹងពួងខ្ពស់គាត់មានឈ្មោះបង្ហាត់សិស្សវិទ្យាល័យនៅផ្គាំហ្នឹង គាត់ធ្វើពាណិជ្ជកម្មផង គាត់មានរោងម៉ាស៊ីនផងអីមិនដឹងទេ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ គាត់រកស៊ីដូចថាវ៉ាលើគេមន្តិចទៅណាស់ ធម្មតាស្រុកហ្នឹងគេមិនចង់ឲ្យយើងលើទេ ។

ប៊ុន ថន៖ បាទ ។

មាស វឿន៖ ហើយគាត់រកស៊ីក៏មិនដើម្បីប្រយោជន៍របស់គាត់ដែរ គាត់រកស៊ីដើម្បីអង្គភាព ដល់ពេលចឹងទៅខ្ញុំមិនថា គាត់នៅហ្នឹងដែរ ដល់ក្រោយបានដឹង ។

ប៊ុន ថន៖ ចឹងកាលអឹមកភ្នំឆត្រែនេះធ្លប់ជួបគាត់ដែរ?

មាស វឿន៖ អត់រហូត ។

ប៊ុន ថន៖ បាទ ។

មាស វឿនៈ អត់មានបានជួបរហូត តែដឹងថាគាត់នៅកន្លែងហ្នឹង ។

ប៊ុន ថនៈ ចឹងកាលមកដល់ដំបូង?

មាស វឿនៈ កាលមកដល់ដំបូងដឹងតែឈ្មោះគាត់ កាលនោះគាត់មានចិញ្ចឹមមាន់ គាត់របៀបកសិកម្ម ចិញ្ចឹមមាន់ គាត់មិនមែនចិញ្ចឹមមួយពីរណា គាត់ចិញ្ចឹមរាប់រយរាប់ពាន់មាន់ គាត់លក់ម្តង ៗរាប់លានខ្មែរ អាតូចដាក់ដោយតូច អាធំដាក់ដោយធំ គាត់ក្ញាស់គាត់មានទ្រុង មានអា ទ្រុងតូចអាទ្រុងធំគាត់ដាក់ របស់គាត់រាប់ពាន់មាន់ណាស់ ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ គាត់លក់ម្តង១រាប់ពាន់ ។

ប៊ុន ថនៈ នៅណា នៅភ្នំឆត្រហ្នឹង?

មាស វឿនៈ បាទ!នៅភ្នំឆត្រហ្នឹង ។

ប៊ុន ថនៈ ចឹងកាលអ៊ីស្គាល់គាត់នៅភ្នំឆត្រ?

មាស វឿនៈ បាទ! ខ្ញុំស្គាល់គាត់នៅភ្នំឆត្របើមីរុំប្រពន្ធស្គាល់យូរហើយ តែមិនដែលបានជួបគ្នាស្គាល់ រាប់ឆ្នាំ ។

ប៊ុន ថនៈ ចឹងគាត់នៅភ្នំឆត្រហ្នឹងបានយូរទេ?

មាស វឿនៈ គាត់នៅភ្នំឆត្រហ្នឹងបានប្រហែលជាមួយឆ្នាំ ធ្វើផ្ទះថ្មឲ្យគាត់នៅ ។

ប៊ុន ថនៈ ចឹងអ៊ំ១ប៉ុល ពតនៅហ្នឹងទេ?

មាស វឿនៈ នៅហ្នឹង ។

ប៊ុន ថនៈ ចឹងនួន ជាមាននៅហ្នឹងដែរ?

មាស វឿនៈ អត់ទេ ប៉ុល ពត ខៀវ សំផននៅជាប់គ្នា ។

ប៊ុន ថនៈ នួន ជា?

មាស វឿនៈ អត់ទេ ។

ប៊ុន ថនៈ ចឹងតា អៀង សារី?

មាស វឿនៈ តា អៀង សារីគាត់នៅម៉ាឡៃជាប់រហូត តាអៀង សារី នួន ជា សុន សេននៅជំរំ ១០០១-១០០២ហ្នឹងនៅដីថៃ តែបើយើងគិតពីដីខ្មែរប្រហែលនៅជាប់គ្នានិងព្រះវិហា ដែលទៅព្រះវិហាដឹងហើយ ។

ប៊ុន ថនៈ ចឹងគាត់បែងចែកគ្នានៅ?

មាស វឿនៈ ហ្នឹងហើយបែងចែកគ្នានៅ ។

ប៊ុន ថន: ចឹងដល់ពេលតា ម៉ុក គាត់ទៅនៅណា?

មាស រឿន: តា ម៉ុក គាត់ទៅនៅអន្លង់វែង ។

ប៊ុន ថន: ចឹងនៅបានមួយឆ្នាំបានគេវៃបែកនេះហ្នឹង?

មាស រឿន: ហ្នឹងហើយព្រោះយើងត្រូវគ្នាហើយប៉ុរាននិងខ្មែរក្រហមត្រូវគ្នារួមរើកងពល ដល់ក្រោយមកទៀតប៉ុរាគេត្រូវគ្នាជាមួយរដ្ឋកម្ពុជា ខុសជាមួយខ្មែរក្រហម គេមកវៃខ្មែរក្រហមពួកឌុល សារឿនអីនេះ នៅខាងជុបគគីរនេះក្រោយគេបង្អស់ហើយ ។

ប៊ុន ថន: បាទ ។

មាស រឿន: វៃហ្នឹងវៃទាំងភ្នំឆត្រវៃជុបគគីរ វៃអន្លង់វែង ។

ប៊ុន ថន: បាទ ។

មាស រឿន: កាលនោះខាងប៉ុរាដឹកនាំរួមវៃហ្នឹងគឺញឹក ប៊ុនឆៃ រួមគ្នាវៃជាមួយកងពលហើយខាងកម្ពុជាកែវ គឹមយ៉ានហ្នឹងឯង ។

ប៊ុន ថន: បាទ ។

មាស រឿន: ហើយខាងប៉ៃលិនហើយនិងម៉ាឡៃគេត្រូវគ្នាជាមួយរដ្ឋកម្ពុជា តែគេមិនបានវៃខាងណាទេ គេនៅស្ងៀម ។

ប៊ុន ថន: ចឹងពេលវៃហ្នឹងនៅហ្នឹងតើ ដល់វៃហ្នឹងបានគាត់រត់ទៅ?

មាស រឿន: បាទ!វៃបែកអាហ្នឹងហើយបានរត់ទៅ វៃបែកអាហ្នឹងហើយវៃអន្លង់វែងជុបគគីរមិនទាន់បែកទេ ។

ប៊ុន ថន: បាទ ។

មាស រឿន: ហើយក្រោយមកទៀតនោះមានពួកជ្រុលនិយម ដឹងទេគេហៅពួកជ្រុលនិយមពួកប៉ុរានោះណាស់ ។

ប៊ុន ថន: បាទ ។

មាស រឿន: ពួកជ្រុលនិយមហ្នឹងទៅវៃគ្នានៅហ្នឹងទៀតជាមួយឌុល សារឿនហ្នឹង ជាមួយលោក ហួតវៃប្រឫកប្របល់គ្នាយករថក្រោះសួរ ចាន់ហេងនេះអស់ពីរគ្រឿងទៀតលួចយកទៅទៀត ។

ប៊ុន ថន: ទៅជាមួយឌុល សារឿន?

មាស រឿន: ហ្នឹងហើយ បែបយកលក់ឲ្យថៃអស់រលីងដឹង ។

ប៊ុន ថន: ចឹងខាងម៉ាឡៃនោះគេត្រូវជាមួយរដ្ឋកម្ពុជា?

មាស រឿនៈ ខាងហ្នឹងគេស្ងាត់ហើយ ហ្នឹងគេត្រូវជាមួយរដ្ឋកម្ពុជាគេនៅស្ងៀមនៅតែខាងនេះទេ ដល់ខាងនោះគេក្ដាប់បានហើយខាងនេះវៃបែកនេះហើយ ឌុល សារឿនគាត់ចចារខ្លួនគាត់ខ្ញុំទៅជាមួយអគ្គការអភិវឌ្ឍន៍ ទៅទទួលឌុល សារឿនហ្នឹងអគ្គការអភិវឌ្ឍន៍នៅស្វាយហ្នឹង ។

ប៊ុន ថនៈ បាទ ។

មាស រឿនៈ ខ្ញុំទៅយកឌុល សារឿនហ្នឹង ឌុល សារឿននៅជុបគគីរលើគេខ្ពស់នោះ ខ្ញុំទៅដេកហ្នឹងមួយយប់ ទំរាំនិយាយចុះចូលគ្នាហើយបានយន្ដហោះសម្ដេចហ៊ុន សែនទៅយកឌុល សរឿនមកទៅភ្នំពេញចប់ត្រឹមហ្នឹងឯង ។

ប៊ុន ថនៈ ចឹងអ៊ីមកនៅទីនេះទៅ?

មាស រឿនៈ ខ្ញុំមកនៅនេះតែរហូតហ្នឹង មកនៅទីនេះតាំងពីត្រូវគ្នាតិចៗតាំងពីអ៊ុន គាក់ចូលនោះ ។

ប៊ុន ថនៈ បាទ ។

មាស រឿនៈ អុន គាក់ចូលហើយខ្ញុំបានបោះឆ្នោតជាប់នវាទិរដ្ឋមន្ត្រីទី១ នោះប្រមូលកំលាំងជួយបោះ ឆ្នោតឲ្យជាប់ដល់ជាប់ទៅមិនដឹងជាយ៉ាងម៉េចបានជានរាទិមិនបានអំណាចវិញ កាលហ្នឹងប្រឫកប្របល់មិនដឹងជាពីងពីណាទេ ។

ប៊ុន ថនៈ ចឹងឥឡូវអ៊ីមកកាន់សាសនាគ្រឹះវិញ?

មាស រឿនៈ បាទ!ថ្ងៃមកនៅខាងគ្រឹះស្ទៀនវិញ ។

ប៊ុន ថនៈ ចឹងអ៊ីចូលខាងគ្រឹះយូរហើយឬនៅ?

មាស រឿនៈ ខ្ញុំប្រហែលជា៧ទៅ៨ឆ្នាំ ខ្ញុំកាលហ្នឹងគេឲ្យធ្វើគណៈបក្សខ្ញុំមិនធ្វើខ្ញុំឈឺក្បាល គេឲ្យធ្វើខាងស្រុកក៏ខ្ញុំមិនធ្វើ ខ្ញុំថាឆ្អែតហើយ ។

ប៊ុន ថនៈ ចឹងអ៊ីរាល់ថ្ងៃមានកូនប៉ុន្មាននាក់?

មាស រឿនៈ កូនខ្ញុំ៨នាក់ ស្លាប់១ នៅសល់៧នាក់ ។

ប៊ុន ថនៈ បាទ ។

មាស រឿនៈ បានការហើយ៣នាក់នៅសល់៤នាក់ទៀត ម្នាក់នៅរៀនបាត់ដំបង ។

ប៊ុន ថនៈ បាទ ។

មាស រឿនៈ ម្នាក់នៅរៀនសាលាបន្ទាយឆ្មារ ហើយម្នាក់ទៀតស្រីហ្នឹងប្រលងបាក់ឌុបហើយអត់មានលុយឲ្យរៀននៅចាំផ្ទះរាល់ថ្ងៃហ្នឹង ។

ប៊ុន ថនៈ បាទ ។

មាស វឿនៈ ហើយកូនមួយទៀតទៅរកស៊ីនៅថៃបាត់ហើយ ខ្ញុំខ្វះខាតលុយខ្ញុំខាយ៉ាប់ ។

ប៊ុន ថនៈ ចឹងអ៊ីរាល់ថ្ងៃហ្នឹងធ្វើស្រែ?

មាស វឿនៈ ខ្ញុំធ្វើស្រែ ។

ប៊ុន ថនៈ ចឹងធ្វើបានប៉ុន្មានហាត់ដែរ?

មាស វឿនៈ ខ្ញុំធ្វើស្រែបាន២ហិចតាហើយទៅធ្វើអីនោះបានប្រហែលជា២ហាត់ដែលដឹង អត់មានបាន ស្រូវទេ ឆ្នាំនេះងាប់អស់ហើយ ។

ប៊ុន ថនៈ ចឹងខ្ញុំអត់មានអីសួរអ៊ីទេ ហើយអរគុណអ៊ីច្រើនដែលចំណាយពេលឲ្យខ្ញុំសម្ភាសន៍ ។

មាស វឿនៈ បាទ ។

**ចប់**